Public Disclosure Authorized

Public Disclosure Authorized

# ព្រះរាជាណាចក្រកម្ពុជា

## គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ

## (LEAP - P153591)

# ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៧

## បុព្វកថា

1. ការអនុវត្តគម្រោង LEAP នឹងត្រូវធ្វើឡើងនៅទីតាំងពីរដែលមានបរិបទនិងការរៀបចំស្ថាប័នខុសគ្នាពោលគឺក្នុងខេត្តសៀមរាបដែលតំបន់ភាគច្រើនជាតំបន់ជនបទ និងក្នុងរាជធានីភ្នំពេញជាទីក្រុងដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ សកម្មភាពស្នូលរបស់គម្រោងនេះនឹងត្រូវបែងចែកជាសមាសភាគជនបទនិងសមាសភាគទីក្រុងដោយមានវិសាលភាពភូមិសាស្ត្រ និងការរៀបចំការអនុវត្តខុសគ្នាទៅតាមបរិបទជាក់លាក់នៃទីកន្លែងនីមួយៗហើយក្នុងពេលជាមួយគ្នា នៅតែរក្សាភាពស៊ីសង្វាក់គ្នានិងនិរន្តរភាពក្នុងគម្រោងទាំងមូល។ ក្រុមអ្នកទទួលផលសំខាន់ៗរបស់គម្រោងនេះគឺគ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារក្រីក្រ (IDPoor)[1] និងគ្រួសារងាយរងគ្រោះក្នុងឃុំគោលដៅចំនួន៤៧ក្នុងខេត្តសៀមរាប និងសង្កាត់គោលដៅចំនួន១៣ក្នុងរាជធានីភ្នំពេញ។

2. ដោយសារតែសកម្មភាពភាគច្រើន ដែលនឹងអនុវត្តក្នុងគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ (LEAP) នេះនឹងត្រូវកំណត់ក្នុងកំឡុងពេលអនុវត្តគម្រោងជាក់ស្តែងផ្អែកទៅតម្រូវការរបស់សហគមន៍ ការរៀបចំផែនការឲ្យបានគត់មុតដើម្បីឆ្លើយតបចំពោះហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតមានឡើងគឺមិនអាចធ្វើទៅបានឡើយ។ ដូច្នេះ ឧបករណ៍ការពារផលប៉ះពាល់ចំនួនពីរត្រូវបានរៀបចំឡើងនោះគឺក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ដែលហៅកាត់ថា ESMF ឬក្របខ័ណ្ឌ) និងក្របខ័ណ្ឌគោលនយោបាយស្តីពីការផ្លាស់ប្តូរការតាំងទីលំនៅ (RPF)[2] ស្របតាមគោលនយោបាយការពារផលប៉ះពាល់របស់ធនាគារពិភពលោក។ ក្របខ័ណ្ឌ ESMF ដាក់ចេញនូវលក្ខខណ្ឌសម្រាប់វាយតម្លៃហានិភ័យបរិស្ថាន និងសង្គមសម្រាប់សកម្មភាពដែលត្រូវទទួលបានហិរញ្ញប្បទានសកម្មភាពគម្រោងដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើប្រជាជននៅមូលដ្ឋាន និងបរិស្ថាននិងការរៀបចំស្ថាប័នដើម្បីអនុវត្តក្របខ័ណ្ឌ ESMF ក្នុងកំឡុងពេលនៃការអនុវត្តគម្រោងនេះ។

3. គម្រោងនេះត្រូវបានវាយតម្លៃថាជាប្រភេទ EA “B” ដោយសារតែសកម្មភាពវិនិយោគនៃគម្រោង LEAP នឹងបង្កឲ្យមានហានិភ័យបរិស្ថាននិងសង្គមតិចតួចបណ្តោះអាសន្ននិងអាចបាត់ទៅវិញដោយខ្លួនឯងដែលអាចគ្រប់គ្រងបាន តាមរយៈ ESMF នេះនិងតាមរយៈក្របខ័ណ្ឌ RPF។ ក្នុងករណីដែលមិនទំនងជាកើតមានឡើងនៅពេលដែលលទ្ធផលនៃការវាយតម្លៃបឋម ឬការវាយតម្លៃគម្រោង

[1]ដោយសារតែការអង្កេត IDPoor ធ្វើឡើងរៀងរាល់បីឆ្នាំម្តង មេឃុំ និងចៅសង្កាត់ ត្រូវបានស្នើឲ្យកំណត់ពីគ្រួសារដែលអាចទទួលផលពីគម្រោងនេះ ពោលគឺជាគ្រួសារដែលអាចធ្លាក់ខ្លួនក្រ ចាប់គិតពីការអង្កេតចុងក្រោយមកដោយសារតែកត្តាសេដ្ឋកិច្ច (ការធ្លាក់ថ្លៃទំនិញ) គ្រោះមហន្តរាយធម្មជាតិ (គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ដំណាំទទួលរងការបំផ្លិចបំផ្លាញ) ឬវិបត្តិផ្សេងទៀត ផ្អែកទៅតាមកម្រងសំណួរ IDPoor។ គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារ IDPoor ថ្មី នឹងត្រូវឆ្លងកាត់តេស្តកំណត់មធ្យមភាគតំណាង (proxy means test) ដោយប្រើប្រាស់វិធីសាស្ត្រ IDPoor ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាពួកគេពិតជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលផលពីគម្រោងនេះ។

[2]*RPF គឺជាផ្នែកមួយនៃ ESMF ហើយនឹងត្រូវបង្ហាញជាឯកសារដោយឡែក។*

នេះរកឃើញថាសកម្មភាពដែលនឹងទទួលបានការគាំទ្រពីគម្រោងនេះ ជាសកម្មភាពដែលមានហានិភ័យខ្ពស់នោះក្រសួងមហាផ្ទៃនឹងទាក់ទងធនាគារពិភពលោក ដើម្បីកំណត់ថាតើសកម្មភាពនេះមានលក្ខណៈសមស្របផ្អែកទៅតាមភាពគួរឲ្យកត់សម្គាល់នៃផលប៉ះពាល់ ដែលអាចកើតមានឡើងហានិភ័យនិងសមត្ថភាពរបស់ទីភ្នាក់ងារអនុវត្តក្នុងការគ្រប់គ្រងហានិភ័យទាំងនេះ។

4. ក្របខ័ណ្ឌ ESMF ត្រូវបានរៀបចំឡើងដោយប្រើប្រាស់ព័ត៌មានដែលបានពីការវិភាគបរិស្ថាន និងសង្គមដែលធ្វើឡើងក្នុងគម្រោង LEAP សាកល្បងដែលអនុវត្តពីឆ្នាំ ២០១០ ដល់ ២០១២។ ក្នុងការត្រៀមរៀបចំសម្រាប់គម្រោងសាកល្បងនេះ និងការពង្រីកវិសាលភាពគម្រោងដែលអាចកើតមានជាយថាហេតុការវាយតម្លៃបរិស្ថាន និងការវាយតម្លៃសង្គមត្រូវបានធ្វើឡើងតាមតំបន់គោលដៅក្នុងខេត្តសៀមរាប។ ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន (EMF) ត្រូវបានរៀបចំឡើងនិងអនុវត្តក្នុងដំណាក់កាលសាកល្បងនេះហើយមេរៀនដែលបានពីការអនុវត្តត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌ ESMF នេះ។ ដោយសារតែទីក្រុងភ្នំពេញត្រូវបានបន្ថែមជាតំបន់គោលដៅរបស់គម្រោង បន្ទាប់ពីដំណាក់កាលសាកល្បងការវាយតម្លៃលើតម្រូវការរបស់សហគមន៍ក្រីក្រក្នុងទីក្រុង ត្រូវបានធ្វើឡើងតាមសហគមន៍មួយចំនួនក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ ២០១៥ ដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរអំពីតម្រូវការរបស់សហគមន៍គោលដៅ ក៏ដូចជាអំពីបរិបទសម្រាប់ឆ្លើយតបទៅនឹងភាពក្រីក្រក្នុងបរិបទទីក្រុង។ ព័ត៌មានដែលបានពីការវាយតម្លៃតម្រូវការនេះត្រូវបានយកទៅប្រើប្រាស់សម្រាប់រៀបចំក្របខ័ណ្ឌ ESMF នេះ រួមទាំង RPF ផងដែរក៏ដូចជាសម្រាប់បញ្ជាប់ការវាយតម្លៃផលជះ (impact evaluation) នៃដំណាក់កាលសាកល្បងដែលផ្តោតខ្លាំងលើការវាស់វែងមូលធនសង្គម ក៏ដូចជាសម្រាប់បន្តពិគ្រោះយោបល់ជាមួយនឹងសហគមន៍ទទួលផលគោលដៅក្នុងខេត្តសៀមរាប និងភ្នំពេញ។

5. ខណៈពេលដែលដំណាក់កាលសាកល្បងពុំបានបញ្ចូលការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចក្នុងសហគមន៍ប្រភេទសកម្មភាពមួយនេះ ត្រូវបានបន្ថែមចូលទៅក្នុងដំណាក់កាលថ្មីដែលត្រូវបានស្នើឡើងសម្រាប់គម្រោងនេះ។ ដូច្នេះក្របខ័ណ្ឌ ESMF នេះប្រើប្រាស់ព័ត៌មានជាច្រើនដែលបានពីការអនុវត្តនីតិវិធីគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថានដែលត្រូវបានធ្វើតេស្តត្រឹមត្រូវ និងដែលត្រូវបានដាក់បញ្ចូលក្នុងសៀវភៅណែនាំអំពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (CSFPIM) ។ មូលនិធិឃុំសង្កាត់បាន និងកំពុងផ្តល់ថវិកាដល់គ្រប់ឃុំសង្កាត់ទាំងអស់ក្នុងប្រទេសនេះចាប់តាំងពីឆ្នាំ ២០០៣ មកសម្រាប់សកម្មភាពផ្សេងៗ ដូចជា កែលំអផ្លូវថ្នល់ការផ្គត់ផ្គង់ទឹកប្រព័ន្ធធារាសាស្ត្រ និងសកម្មភាពផ្សេងទៀតស្របតាមសកម្មភាពដែលត្រូវទទួលបានថវិកាគាំទ្រក្រោមគម្រោង LEAP នេះ។ CSFPIM ត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយក្នុងឆ្នាំ ២០០៩។ នីតិវិធីនិងទម្រង់ពាក់ព័ន្ធដែលមានក្នុង CSFPIM នឹងត្រូវយកមកប្រើប្រាស់សម្រាប់អនុវត្តសកម្មភាពហេដ្ឋារចនាសម្ព័ន្ធសហគមន៍ក្រោមគម្រោង LEAP នេះ។ បន្ថែមពីលើអ្វីដែលមានក្នុង CSFPIM ក្របខ័ណ្ឌ ESMF និង RPF ក៏ដាក់បញ្ចូលផងដែរនូវវិធានការសម្រាប់កំណត់និងគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមរបស់សកម្មភាពផ្សេងទៀតដែលបានទទួលថវិកាគាំទ្រពីគម្រោងនេះដែរប៉ុន្តែមិនបានដាក់បញ្ចូលក្នុង CSFPIM ជាពិសេសការវិនិយោគលើសកម្មភាពចិញ្ចឹមជីវិតខ្នាតតូចដែលធ្វើឡើងដោយគ្រួសារនីមួយៗដោយក្រុមជួយខ្លួនឯង និងក្រុម

អ្នកផលិត។ ក្រសួងមហាផ្ទៃជាអ្នកទទួលខុសត្រូវដើម្បីធានាយ៉ាងណាឲ្យមានការអនុវត្ត និងគោរពតាមអ្វីដែលបានដាក់ចេញក្នុងក្របខ័ណ្ឌ ESMF នេះក្នុងកំឡុងពេលអនុវត្តគម្រោង។

6. ក្របខ័ណ្ឌ ESMF នេះត្រូវបានរៀបចំឡើងផ្អែកទៅតាមមេរៀនដែលទទួលបានពីគម្រោង LEAP សាកល្បងនិងពីការវាយតម្លៃបរិស្ថានដែលធ្វើឡើងនៅដំណាក់កាលផ្សេងៗនៃការរៀបចំគម្រោងនេះ។ ក្របខ័ណ្ឌ ESMF នេះនឹងត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសៀវភៅណែនាំអំពីការអនុវត្តគម្រោង (PIM) សម្រាប់គម្រោង LEAP នេះ។ ឯកសារ ESMF នេះគឺជាឯកសាររស់ដែលអាចកែសម្រួលឲ្យស្របតាមការផ្លាស់ប្តូរប្រភេទនៃសកម្មភាពគម្រោង។ នេះពេលដែលស្ថានភាពតម្រូវឲ្យមានការកែសម្រួលក្របខ័ណ្ឌ ESMF នេះនឹងមានការពិគ្រោះយោបល់ជាមួយធនាគារពិភពលោកសិនមុនពេលមានការកែសម្រួលហើយការផ្លាស់ប្តូរឬការកែសម្រួលចំពោះក្របខ័ណ្ឌនេះ ESMF ត្រូវមានការផ្តល់ការមិនជំទាស់ (No-Objection) ពីធនាគារពិភពលោកសិន។

# មាតិកា

ផ្នែកទី I ៖ សេចក្តីផ្តើម ........ 8
ផ្នែកទី II ៖ សេចក្តីពិពណ៌នាអំពីគម្រោង ........ 9
ផ្នែកទី III ៖ ស្ថានភាពសង្គម និងបរិស្ថានសំខាន់ៗ ........ 30
ផ្នែកទី IV ៖ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ ........ 53
ផ្នែកទី V ៖ មេរៀនដែលទទួលបានពីការអនុវត្តគម្រោង LEAP សាកល្បង ........ 64
ផ្នែកទី VI ៖ ផលប៉ះពាល់សំខាន់ៗមកលើបរិស្ថាន និងសង្គម ........ 67
ផ្នែកទី VII ៖ គោលការណ៍ និងនីតិវិធីសម្រាប់វាយតម្លៃ និងកាត់បន្ថយផលប៉ះពាល់ក្រោមគម្រោង LEAP ........ 75
ផ្នែកទី VIII ៖ ការរៀបចំស្ថាប័ន ........ 83
ផ្នែកទី IX ៖ ការពិគ្រោះយោបល់ជាសាធារណៈការបង្ហាញព័ត៌មានជាសាធារណៈ និងយន្តការដោះស្រាយបណ្តឹង ........ 88
ផ្នែកទី X ៖ ការរៀបចំការអង្កេតតាមដាន និងការរាយការណ៍ ........ 90
ឧបសម្ព័ន្ធ ........ 91

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| AC | Agricultural Cooperatives | សហករណ៍កសិកម្ម |
| CCs | Commune Councils | ក្រុមប្រឹក្សាឃុំ |
| CLF | Commune Level Federations | សហព័ន្ធកម្រិតឃុំ |
| CLIF | Community Livelihood Investment Fund | មូលនិធិវិនិយោគលើមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍ |
| CP | Community Professional | អ្នកជំនាញខាងសហគមន៍ |
| C/SF | Commune/Sangkat Fund | មូលនិធិឃុំសង្កាត់ |
| EMP | Environment Management Plan | ផែនការគ្រប់គ្រងបរិស្ថាន |
| ESMF | Environmental and Social Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម |
| IDA | International Development Association | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IDPoor | Poverty Identification Process | ដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |
| EIA | Environmental Impact Assessment | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន |
| EMF | Environmental Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន |
| IEIA | Initial Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម |
| IPM | Integrated Pest Management | ការគ្រប់គ្រងសមាសភាគចង្រៃបែបចម្រុះ |
| IRM | Immediate Response Mechanism | យន្តការឆ្លើយតបបន្ទាន់ |
| LEAP | Livelihood Enhancement and Association of the Poor Project | គម្រោងលើកកម្ពស់ជីវភាពរស់នៅនិងសមាគមប្រជាជនក្រីក្រ |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាននិងវាយតម្លៃ |
| MAFF | Ministry of Agriculture, Fisheries and Forestry | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| MFIs | Microfinance Institutions | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MIP | Micro Investment Plans | ផែនការវិនិយោគខ្នាតតូច |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDDS | National Committee for Sub-National Democratic Development Secretariat | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NGO | Non-Government Organization | អង្គការមិនមែនរដ្ឋាភិបាល |

| | | |
|---|---|---|
| PG | Producer Group | ក្រុមអ្នកផលិត |
| PIM | Project Implementation Manual | សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង |
| PPC | Phnom Penh Capital | រាជធានីភ្នំពេញ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RPF | Resettlement Policy Framework | ក្របខ័ណ្ឌគោលនយោបាយស្តីពីការផ្លាស់ប្តូរការតាំងទីលំនៅ |
| SHG | Self-Help Group | ក្រុមជួយខ្លួនឯង |
| SMT | Sub-Management Teams | អនុក្រុមគ្រប់គ្រង |
| TEGs | Technical Environmental Guidelines | *គោលការណ៍ណែនាំបច្ចេកទេសស្តីពីបរិស្ថាន* |
| TSSD | Tonle Sap Poverty Reduction and Smallholder Development | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជីវភាពគ្រួសារកសិករនៅតំបន់ទន្លេសាប |
| UPCs | Urban Poor Communities | សហគមន៍ក្រីក្រក្នុងទីក្រុង |
| WB | World Bank | ធនាគារពិភពលោក |

# ផ្នែកទី I ៖ សេចក្តីផ្តើម

## 1.1 គោលបំណងនៃក្របខ័ណ្ឌ ESMF

1. ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ដែលហៅកាត់ថា ESMF) នេះមានគោលបំណងធានាយ៉ាងណាឲ្យសកម្មភាពក្នុងគម្រោង LEAP បានឆ្លងកាត់ការត្រួតពិនិត្យដើម្បីរកផលប៉ះពាល់អវិជ្ជមានខាងសង្គមនិងបរិស្ថាន និងមានការពិចារណាលើវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះក្នុងការរៀបចំនិងអនុវត្តសកម្មភាព។ និយាយមួយបែបទៀតក្របខ័ណ្ឌ ESMF នេះត្រូវបានរៀបចំឡើងដើម្បីធានាយ៉ាងណាឲ្យការវិនិយោគដែលធ្វើឡើងដោយគម្រោង LEAP មិនបង្កើត ឬបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានលើសកម្មភាពរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងបរិស្ថានឡើយ ហើយមានការកំណត់បញ្ចៀសឬយ៉ាងណាស់បានកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើង។ ជាពិសេសក្របខ័ណ្ឌ ESMF នេះ មានគោលបំណងដាក់ចេញនូវដំណើរការត្រួតពិនិត្យបឋម និងគោលការណ៍ណែនាំស្តីពីបរិស្ថាន និងសង្គមក្នុងគោលបំណង ៖

(ក) ទប់ស្កាត់ និង/ឬកាត់បន្ថយផលប៉ះពាល់ខាងបរិស្ថាន និងសង្គមដែលអាចកើតឡើងចេញពីសកម្មភាពដែលបានស្នើឡើង

(ខ) ធានាយ៉ាងណាឲ្យប្រយោជន៍ ដែលបានពីសកម្មភាពដែលស្នើឡើងមាននិរន្តរភាពបរិស្ថានរយៈពេលវែងតាមរយៈការធានាមូលដ្ឋានធនធានធម្មជាតិ ដែលសកម្មភាពទាំងនេះពឹងអាស្រ័យលើ និង

(គ) សម្របសម្រួលតាមបែបផ្តួចផ្តើមជាងមុននូវសកម្មភាពទាំងឡាយ ដែលគេរំពឹងថានឹងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ និងការកែលំអការគ្រប់គ្រងធនធានធម្មជាតិដែលនាំឲ្យមានគុណភាពបរិស្ថាននៅមូលដ្ឋាន និងសុខុមាលភាពមនុស្សមានស្ថិរភាពជាប់លាប់ និង/ឬបន្តមានការកែលំអជាបន្តបន្ទាប់។

2. ក្របខ័ណ្ឌ ESMF នេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់មេរៀនដែលទទួលបានពីដំណាក់កាលទី១ ដែលធ្វើឡើងក្នុងឆ្នាំ ២០១០ សម្រាប់ផ្តល់ជាព័ត៌មានដល់ការរៀបចំគម្រោង LEAP ក្នុងខេត្តសៀមរាប។ នីតិវិធីពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម និងទម្រង់បែបបទក្នុងសៀវភៅណែនាំស្តីពីការអនុវត្តមូលនិធិឃុំសង្កាត់ (CSFPIM) ត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌ ESMF នេះ។ CSFPIM ក៏ត្រូវបានរៀបចំឡើងដោយផ្អែកលើច្បាប់ស្តីពីបរិស្ថាន និងសង្គមរបស់ប្រទេសកម្ពុជាក៏ដូចជាមេរៀនដែលបានពីការអនុវត្តការងារ និងការការពារផលប៉ះពាល់របស់ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី ដែលកន្លងមកបានយក CSFPIM នេះទៅប្រើប្រាស់ផងដែរ។ CSFPIM ត្រូវបានរៀបចំឡើងនិងធ្វើបច្ចុប្បន្នភាពចុងក្រោយគេក្នុងឆ្នាំ ២០០៩ ដើម្បីផ្តល់ការតម្រង់ទិសឲ្យគម្រោងវិនិយោគឃុំសង្កាត់មានលក្ខណៈស្របគ្នាជាមួយនឹងស្តង់ដារអន្តរជាតិនៃការអនុវត្តការងារអភិវឌ្ឍន៍ ដែលអាចធានាបាននូវនិរន្តរភាពខាងបរិស្ថាននិងសង្គម។ CSFPIM តម្រូវឲ្យមានការអនុវត្ត "ការត្រួតពិនិត្យខាងបរិស្ថាននិងសង្គម" "ការវិភាគបរិស្ថាន" ក៏ដូចជា "ការសិក្សាពីដីធ្លី" ដែលជាផ្នែកមួយនៃប្រព័ន្ធវិនិយោគលើការ

អភិវឌ្ឍឃុំនៅថ្នាក់ក្រោមជាតិ។ ដូច្នេះ សកម្មភាពដែលរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិកំណត់ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមានលើប្រជាពលរដ្ឋនៅមូលដ្ឋាន និងបរិស្ថាននៅកន្លែងដែលអនុគម្រោងត្រូវបានស្នើអនុវត្តត្រូវបានចាត់ទុកថាជាសកម្មភាពដែលមានលក្ខណៈសមស្របដើម្បីទទួលបានថវិកាគាំទ្រពីគម្រោងនេះ ក៏ដូចជាការរៀបចំស្ថាប័នដើម្បីអនុវត្តក្របខ័ណ្ឌ ESMF នេះក្នុងកំឡុងរយៈពេលនៃការអនុវត្តគម្រោងនេះ។

# ផ្នែកទី II ៖ សេចក្ដីពិពណ៌នាអំពីគម្រោង

## 2.1 គោលបំណងនៃការរៀបចំគម្រោង

3. គោលបំណងនៃការរៀបចំគម្រោង (PDO) គឺដើម្បីបង្កើនលទ្ធភាពរបស់គ្រួសារក្រីក្រនិងងាយរងគ្រោះនៅតាមសហគមន៍មួយចំនួនក្នុងការទទួលបានសេវាហិរញ្ញវត្ថុ ឱកាសរកចំណូល និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ក៏ដូចជាផ្ដល់ការឆ្លើយតបភ្លាមៗប្រកបដោយប្រសិទ្ធភាពក្នុងករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្នកើតឡើងដែលសមស្របដើម្បីទទួលបានការគាំទ្រពីគម្រោង។

## 2.2 អ្នកទទួលផលរបស់គម្រោង

4. អ្នកទទួលផលគម្រោងសំខាន់ៗរបស់គម្រោងនេះគឺគ្រួសារ IDPoor[3] និងគ្រួសារងាយរងគ្រោះនៅតាមឃុំគោលដៅចំនួន ៤៧ ក្នុងខេត្តសៀមរាប និងសង្កាត់គោលដៅចំនួន ១៣ ក្នុងរាជធានីភ្នំពេញ។

5. អ្នកទទួលផលក្នុងខេត្តសៀមរាបគឺជាគ្រួសារមកពី ៤៧ ឃុំដែលមិនបានទទួលការគាំទ្រពីគម្រោង TSSD។ មានឃុំចំនួន ៤២ មិនបានទទួលការគាំទ្រពីគម្រោង TSSD ហើយនឹងទទួលបានការគ្របដណ្ដប់ទាំងស្រុងពីគម្រោង LEAP ។ ភូមិក្នុងឃុំចំនួន ៥ ដែលមិនត្រូវបានគ្របដណ្ដប់ទាំងស្រុងដោយគម្រោង TSSD ប៉ុន្តែមានភាពក្រីក្រលើសពីកម្រិតមធ្យមនឹងត្រូវដាក់បញ្ចូលក្នុងគម្រោង LEAP ។ អ្នកទទួលផលក្នុងរាជធានីភ្នំពេញគឺជាគ្រួសារមកពីសង្កាត់ចំនួន ១៣ ដែលត្រូវបានជ្រើសរើសដូចខាងក្រោម៖ (ក) សម្រាប់ខណ្ឌចំនួន ៨ ដែលមានទិន្នន័យ IDPoor សង្កាត់ដែលមានចំនួនគ្រួសារ IDPoor សរុបច្រើនជាងគេត្រូវបានជ្រើសរើស ដើម្បីបញ្ចូលក្នុងគម្រោងនេះ ពោលគឺជ្រើសរើសសង្កាត់មួយពីខណ្ឌទាំង ៦ ដែលមាន ១០ សង្កាត់ ឬតិចជាងនេះ និងសង្កាត់ពីរពីខណ្ឌនីមួយៗក្នុងចំណោមខណ្ឌ

[3] ដោយសារតែការអង្កេត IDPoor ធ្វើឡើងរៀងរាល់បីឆ្នាំម្ដង មេឃុំ និងចៅសង្កាត់ ត្រូវបានស្នើឲ្យកំណត់ពីគ្រួសារដែលអាចទទួលផលពីគម្រោងនេះ ពោលគឺជាគ្រួសារដែលអាចធ្លាក់ខ្លួនក្រ ចាប់គិតពីការអង្កេតចុងក្រោយមកដោយសារតែកត្តាសេដ្ឋកិច្ច (ការធ្លាក់ថ្លៃទំនិញ) គ្រោះមហន្តរាយធម្មជាតិ (គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ដំណាំទទួលរងការបំផ្លិចបំផ្លាញ) ឬវិបត្តិផ្សេងទៀត ផ្អែកទៅតាមកម្រងសំណួរ IDPoor។ គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារ IDPoor ថ្មី នឹងត្រូវឆ្លងកាត់តេស្តកំណត់មធ្យមភាគតំណាង (proxy means test) ដោយប្រើប្រាស់វិធីសាស្ត្រ IDPoor ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាពួកគេពិតជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលផលពីគម្រោងនេះ។

ចំនួនពីរដែលមានច្រើនជាង ១០ សង្កាត់។ (ខ) ក្នុងខណ្ឌ ៤ ដែលពុំមានទិន្នន័យ IDPoor ដោយសារតែខណ្ឌទាំងនោះស្ថិតនៅចំកណ្តាលក្រុង សង្កាត់ចំនួនមួយត្រូវបានជ្រើសរើសចេញពីខណ្ឌណាមួយដែលមានចំនួនគ្រួសារច្រើនជាងគេក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ទៅតាមការកំណត់ដោយរាជធានីភ្នំពេញ។ តាមរយៈការប្រើប្រាស់ទិន្នន័យ IDPoor និងលក្ខណវិនិច្ឆ័យ UPC ផ្តល់លទ្ធភាពឲ្យមានការដាក់បញ្ចូលខណ្ឌជាយក្រុងនិងខណ្ឌកណ្តាលក្រុងដែរ។ ចំណុចដៅដែលមានកម្រិតទាបសម្រាប់វិសាលភាពក្នុងរាជធានីភ្នំពេញត្រូវបានកំណត់ដោយមានគោលបំណង ដើម្បីផ្តល់លទ្ធភាពឲ្យមានការសាកល្បងសកម្មភាពគម្រោងក្នុងបរិបទទីក្រុង ដោយអាចពង្រីកបន្ថែមទៀតដោយផ្អែកលើបទពិសោធន៍នៃការអនុវត្តល្អនៅពេលដែលគម្រោងមានការរីកចម្រើនទៅមុខ។

6. គ្រួសារ IDPoor ដែលជាសមាជិកក្រុមជួយខ្លួនឯង ក្រុមអ្នកផលិតនិងសហករណ៍កសិកម្មដែលមានស្រាប់ និងដែលនឹងត្រូវបង្កើតថ្មីគឺជាអ្នកទទួលផលចម្បងរបស់គម្រោងនេះក្នុងខេត្តសៀមរាប។ គ្រួសារ ID Poor នឹងក្លាយជាអ្នកទទួលផលទីមួយក្នុងការអភិវឌ្ឍជំនាញ និងជំនួយការងារដោយមានការប្រើប្រាស់បន្ថែមនូវការធ្វើតេស្តដោយប្រើប្រាស់រង្វាស់តំណាង (proxy means) លើអ្នកដែលដាក់ពាក្យធ្វើជាអ្នកទទួលផលរបស់គម្រោងដែលគ្មានប័ណ្ណក្រីក្រ ប៉ុន្តែនៅតែបំពេញលក្ខណវិនិច្ឆ័យ ID Poor។ គេរំពឹងថាគ្រួសារក្នុងឃុំ/សង្កាត់ទាំងនេះ នឹងទទួលបានប្រយោជន៍ពីការកែលំអហេដ្ឋារចនា-សម្ព័ន្ធដែលស្ថិតក្នុងផែនការគម្រោងប៉ុន្តែនឹងមានការផ្តល់អាទិភាពដល់គ្រួសារ IDPoor ដើម្បីធានាយ៉ាងណាឲ្យគ្រួសារទាំងនេះអាចទទួលបានប្រយោជន៍ជាងគេ។ មិនមែនសហគមន៍ទាំងអស់សុទ្ធតែអាចទទួលបានហេដ្ឋារចនាសម្ព័ន្ធសហគមន៍នោះទេ។ មានតែសហគមន៍ដែលកំណត់ថាតាំងទីលំនៅអចិន្ត្រៃយ៍ប៉ុណ្ណោះដែលមានសិទ្ធិទទួលបាន។

## 2.3 សេចក្តីពិពណ៌នាអំពីគម្រោង

7. ការអនុវត្តគម្រោង LEAP នឹងត្រូវធ្វើឡើងនៅទីតាំងពីរដែលមានបរិបទ និងការរៀបចំស្ថាប័នខុសគ្នាពោលគឺក្នុងខេត្តសៀមរាបដែលតំបន់ភាគច្រើនជាតំបន់ជនបទ និងក្នុងរាជធានីភ្នំពេញ ជាទីក្រុងដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ សកម្មភាពស្នូលរបស់គម្រោងនេះនឹងត្រូវបែងចែកជាសមាសភាគជនបទ និងសមាសភាគទីក្រុងដោយមានវិសាលភាពភូមិសាស្ត្រនិងការរៀបចំការអនុវត្តខុសគ្នាទៅតាមបរិបទជាក់លាក់នៃទីកន្លែងនីមួយៗ ហើយក្នុងពេលជាមួយគ្នានៅតែរក្សាភាពស៊ីសង្វាក់គ្នានិងនិរន្តរភាពក្នុងគម្រោងទាំងមូល។

## 2.4 សមាសភាគគម្រោង

8. ការអនុវត្តគម្រោង LEAP នឹងត្រូវធ្វើឡើងនៅទីតាំងពីរដែលមានបរិបទនិងការរៀបចំស្ថាប័នខុសគ្នាពោលគឺក្នុងខេត្តសៀមរាបដែលតំបន់ភាគច្រើនជាតំបន់ជនបទ និងក្នុងរាជធានីភ្នំពេញជាទីក្រុងដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ សកម្មភាពស្នូលរបស់គម្រោងនេះនឹងត្រូវបែងចែកជាសមាសភាគជនបទនិងសមាសភាគទីក្រុង ដោយមានវិសាលភាពភូមិសាស្ត្រ និងការរៀបចំការអនុវត្ត

ខុសគ្នាទៅតាមបរិបទជាក់លាក់នៃទីកន្លែងនីមួយៗហើយក្នុងពេលជាមួយគ្នា នៅតែរក្សាភាពស៊ីសង្វាក់គ្នា និងនិរន្តរភាពក្នុងគម្រោងទាំងមូល។

9. សមាសភាគទីមួយគឺជាសមាសភាគជនបទ និងត្រូវបានអនុវត្តដោយអាជ្ញាធរខេត្តសៀមរាប ដែលនឹងគ្របដណ្តប់លើឃុំ ៤៧ (រួមទាំង ឃុំ ៦ ដែលរួមបញ្ចូលក្នុងគម្រោងសាកល្បង LEAP) ដែលមិនទាន់ទទួលបានជំនួយពីគម្រោងអភិវឌ្ឍន៍កសិករខ្នាតតូច និងការកាត់បន្ថយភាពក្រីក្រតាមដងទន្លេសាប (TSSD)។ សមាសភាគទី ២ គឺសមាសភាគទីប្រជុំជន និងត្រូវអនុវត្តដោយរដ្ឋាភិបាលក្រុងភ្នំពេញក្នុងសង្កាត់ ១៣ (ឃុំប្រជុំជន)។ សមាសភាគទី ៣ នឹងគាំទ្រដល់ការគ្រប់គ្រងគម្រោងទាំងមូល និងសកម្មភាពរដ្ឋបាល ដូចជា ការសម្របសម្រួលថ្នាក់ក្រោមជាតិ ការសម្របសម្រួលអន្តររដ្ឋាភិបាល ការធានាការពារ និងការគ្រប់គ្រង និងត្រួតពិនិត្យត្រឹមត្រូវ និងការពិនិត្យតាមដាន និងវាយតម្លៃ។ សមាសភាគទី ៤ ជាផ្នែកមួយនៃជំនួយរបស់ IDA លើយន្តការឆ្លើយតបភ្លាមៗ (IRM) នៅកម្ពុជា។ សមាសភាគនេះមិនទាន់ទទួលបានជំនួយថវិកាឡើយ។ ប៉ុន្តែប្រសិនបើមានសំណើផ្លូវការពីរដ្ឋាភិបាលសម្រាប់ករណីបន្ទាន់នៅថ្ងៃខាងមុខ សមាសធាតុនេះនឹងផ្តល់លទ្ធភាពឲ្យមានការបែងចែកឡើងវិញនូវចំណែកសមតុល្យគម្រោងដែលគ្មានចំណាយសម្រាប់ការស្តារ និងសាងសង់ឡើងវិញ។

10. **សមាសភាគទី ១ ៖ ការលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រនិងងាយរងគ្រោះនៅជនបទ (១៤,៤៨លានដុល្លារ)** - សមាសភាគនេះមានគោលបំណងឆ្លើយតបចំពោះតម្រូវការរបស់គ្រួសារ IDPoor និងគ្រួសារងាយរងគ្រោះក្នុងឃុំចំនួន ៤៧ ក្នុងខេត្តសៀមរាប ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកទៅតាមតម្រូវការ។ សកម្មភាពរួមមាន៖ (ក) ផ្តល់ការគាំទ្រជាការកសាងស្ថាប័ននិងកសាងសមត្ថភាពដល់ក្រុមជួយខ្លួនឯងក្រុមអ្នកផលិត និងសហករណ៍កសិកម្ម (ខ) ផ្តល់ថវិកាជាទុនសម្រាប់អនុគម្រោងមុខរបរចិញ្ចឹមជីវិត (គ) ធ្វើការសិក្សាទីផ្សារ (ឃ) ការពង្រីកសេវាគាំទ្រអាជីវកម្ម (ង) ការបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញ (ច) សេវាគាំទ្រដល់ការងារ/មុខរបរ និង (ង) ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដែលមានប្រយោជន៍ដើម្បីលើកកម្ពស់មុខរបរចិញ្ចឹមជីវិត និងបង្កើនផលិតភាព។ ដោយសារតែរបរកសិកម្មចិញ្ចឹមសត្វនិងនេសាទគឺជាប្រភពចំណូលចម្បង សម្រាប់គ្រួសារក្រីក្រតាមទីជនបទទាំងនេះគម្រោងនេះនឹងស្នើសុំការគាំទ្របច្ចេកទេសពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងអ្នកផ្តល់សេវាបច្ចេកទេសផ្សេងទៀត។ ដោយប្រើប្រាស់បទពិសោធន៍ដែលបានពីគម្រោងសាកល្បង LEAP សមាសភាគនេះនឹងត្រូវអនុវត្តដោយអាជ្ញាធរខេត្តសៀមរាបតាមរយៈអនុសមាសភាគខាងក្រោម៖

11. ***អនុសមាសភាគទី ១.១ ៖ កសាងនិងពង្រឹងក្រុម/សមាគមប្រជាពលរដ្ឋក្រីក្រនៅជនបទ (៨,២៧លានដុល្លា) ៖*** សមាសភាគនេះនឹងគាំទ្រដល់ការបង្កើតនិងពង្រឹងស្ថាប័នស្វ័យគ្រប់គ្រង និងបំពេញមុខងារល្អប្រសើររបស់ប្រជាជនក្រីក្រ និងជំរុញឲ្យសមាជិកចូលរួមជារួម ឬជាបុគ្គលក្នុងសកម្មភាពផលិតកម្ម។ ក្រុមជួយខ្លួនឯងនឹងទទួលបានជំនួយបឋមក្នុងសកម្មភាពសន្សំ និងឥណទានសំដៅទៅបង្កើតសហព័ន្ធកម្រិតឃុំ និងសហករណ៍ ដូចជា ក្រុមផលិត ឬសហករណ៍កសិកម្ម។ សេវារបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ឬអ្នកផ្តល់សេវាឯកជនផ្សេងទៀតនឹងបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញ និងកៀរគរអ្នកទទួលផលសម្រាប់ការបង្កើតក្រុម ដោយធានា

នូវការដឹកនាំ និងការត្រួតពិនិត្យ និងផ្តល់ការណែនាំ និងការអភិវឌ្ឍសមត្ថភាពឲ្យមាននិរន្តរភាព។ បុគ្គលិកជំនួយការនឹងស្ថិតនៅតាមឃុំដើម្បីសម្របសម្រួលការបង្កើតក្រុម ការបង្កើនការយល់ដឹង និងបណ្តុះបណ្តាល និងប្រតិបត្តិការរបស់ក្រុមឥណទាន និងក្រុមសន្សំ។ ក្រៅពីនេះ មានការផ្តល់ជំនួយទៅតាមតម្រូវការលើការបង្កើត និងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមផលិតក្រៅផ្លូវការ ឬសហករណ៍កសិកម្មផ្លូវការ។ ក្រុមទាំងនេះ និងកសិករជាបុគ្គលនឹងទទួលបានជំនួយ និងពង្រឹងតាមរយៈការសម្របសម្រួលបង្កើតទំនាក់ទំនងទីផ្សារ ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពដល់អ្នកផលិតដើម្បីបង្កើនលទ្ធភាពទ្រព្យសម្បត្តិ ជំនាញ បច្ចេកវិទ្យា និងទីផ្សារក្នុងសង្វាក់តម្លៃសំខាន់ៗ។

*ការកៀរគរ ការបង្កើត និងការបណ្តុះបណ្តាលក្រុមជួយខ្លួនឯង*

12. អ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាលនឹងចូលរួមក្នុងការបង្កើតក្រុម និងការកសាងសមត្ថភាពរបស់ក្រុមជួយខ្លួនឯង និងក្រុមអ្នកទទួលផលផ្សេងទៀត (ក្រុមផលិត សហករណ៍កសិកម្ម។ល។)។ ពួកគេនឹងគ្របដណ្តប់លើបណ្តុះភូមិសាស្ត្រជិតៗដែលមាន ១០ ឃុំ និងទទួលបានជំនួយពីអ្នកសម្របសម្រួលថ្នាក់ស្រុក (DFs) និងក្រុមប្រឹក្សាឃុំ និងមន្ត្រីបង្គោលសហគមន៍ ដូចជា អ្នកជំនាញសហគមន៍ (CPs) និងអ្នកផ្សព្វផ្សាយឃុំ (CEWs)។

13. អ្នកសម្របសម្រួលថ្នាក់ស្រុកនឹងធ្វើកិច្ចសន្យាជាមួយក្រុមគ្រប់គ្រងរងខេត្តសៀមរាប (SMT) សម្រាប់ស្រុកគោលដៅនីមួយៗដើម្បីសម្របសម្រួល និងគាំទ្រសកម្មភាពគម្រោង។ ពួកគេនឹងសម្របសម្រួលជាមួយអ្នកផ្តល់សេវាអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំដើម្បីសម្រួលដល់ការចូលរួមរបស់ពួកគេ។ ក្រុមប្រឹក្សាឃុំនឹងដើរតួនាទីសំខាន់ក្នុងការកំណត់គ្រួសារ IDPoor និងការបង្កើតក្រុមជួយខ្លួនឯង ខណៈដែលអ្នកជំនាញតាមភូមិ និងសហគមន៍ និងអ្នកផ្សព្វផ្សាយឃុំដែលមានបទពិសោធន៍ក្នុងការកៀរគរសង្គមនឹងត្រូវបានកំណត់ និងបណ្តុះបណ្តាលឲ្យធ្វើជាគ្រូបង្គោលសម្រាប់ក្រុមជួយខ្លួនឯង និងក្រុមប្រកបរបរចិញ្ចឹមជីវិតផ្សេងទៀត។

*ការបង្កើតសមាគមភូមិ និងសហព័ន្ធឃុំ*

14. គម្រោងនឹងជំរុញឲ្យក្រុមជួយខ្លួនឯង និងសមាជិកបង្កើតសហព័ន្ធនៅតាមឃុំ។ ការបង្កើតសហព័ន្ធនឹងជំរុញឲ្យពួកគេចូលរួមជាមួយអ្នកផ្តល់សេវាបច្ចេកទេស និងហិរញ្ញវត្ថុសាធារណៈ និងឯកជននៅកម្រិតខ្ពស់។ ក្រុមផលិត និងសហករណ៍កសិកម្មគឺជាស្ថាប័នដែលមានការទទួលស្គាល់ ដែលទទួលបានជំនួយសាធារណៈ និងអាចជាដៃគូមានប្រសិទ្ធភាពសម្រាប់អាជីវកម្មវិស័យឯកជន។ គម្រោងនឹងពាក់ព័ន្ធនឹងសេវារបស់អង្គការមិនមែនរដ្ឋាភិបាល នាយកដ្ឋានសហករណ៍កសិកម្ម និងអ្នកផ្តល់សេវាឯកជន និងសាធារណៈផ្សេងទៀតដើម្បីរៀបចំវគ្គបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពសម្រាប់សហព័ន្ធទាំងនេះ។

## *លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការសម្របសម្រួលទំនាក់ទំនងជាមួយវិស័យហិរញ្ញវត្ថុផ្លូវការ*

15. ក្រុមជួយខ្លួនឯង និងសហព័ន្ធរបស់ក្រុមអ្នកទទួលផលនឹងក្លាយជាចំណុចចាប់ផ្ដើមក្នុងការបង្កើនលទ្ធភាពរបស់ប្រជាជនក្រីក្រក្នុងការទទួលបានសេវាហិរញ្ញវត្ថុ។ មុខងារសន្សំ និងឥណទានរបស់ក្រុមទាំងនេះនឹងជួយពួកគេឲ្យទទួលបានបទពិសោធន៍ក្នុងការវិនិយោគខ្នាតតូច បង្កើតប្រវត្តិឥណទានសម្រាប់គ្រួសារក្រីក្រ និងជួយផ្លាស់ប្ដូរការយល់ឃើញពីហានិភ័យរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ។ ក្រោមគម្រោងនេះ គ្រួសារទទួលផលនឹងមានសមត្ថភាពប្រើប្រាស់ប្រាក់សន្សំដំបូងរបស់ខ្លួនសម្រាប់ការបង្កើតក្រុមជួយខ្លួនឯង និងផ្ដល់កម្ចីក្នុងក្រុម។ សម្រាប់ក្រុមជួយខ្លួនឯងដែលសម្រេចបានប្រសិទ្ធភាព និងបង្កើតផែនការវិនិយោគខ្នាតតូច (MIPs) សម្រាប់សមាជិកគ្រួសារតាមរយៈដំណើរការដែលមានការចូលរួម គម្រោងនឹងបំពេញបន្ថែមលើប្រាក់សន្សំរបស់ក្រុមជួយខ្លួនឯងជាគ្រាប់ពូជទៅតាមតម្រូវការ។ ទំហំជំនួយនេះនឹងកំណត់ដោយចំនួនសមាជិក និងមានមានរហូតដល់ ១.០០០-១.៥០០ ដុល្លាក្នុងមួយក្រុម (សមាជិក ១០-១៥ នាក់/ក្រុម)។ ក្រុមប្រឹក្សាឃុំនឹងជួយដល់ការពិនិត្យសំណើមូលនិធិដំបូង និងកំណត់ហានិភ័យដែលត្រូវពិចារណាដោយ SMT ក្នុងការសម្រេចចិត្ត។ CPs និង CEWs នឹងជួយដល់ក្រុមប្រឹក្សាឃុំក្នុងការពិនិត្យសំណើ/MIPs ពីក្រុមជួយខ្លួនឯង។

16. ក្នុងករណីដែលសហព័ន្ធថ្នាក់ឃុំ (CLFs) ត្រូវបានបង្កើតឡើង និងសម្រេចបំពេញតួនាទីកម្ចីបន្តគម្រោងនេះនឹងផ្ដល់ឲ្យពួកគេនូវថវិកាជំនួយ ដែលបានពីមូលនិធិវិនិយោគលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ (CLIF) រហូតដល់ ៣៧.០០០ ដុល្លារក្នុងមួយសហព័ន្ធ។ ថវិកាជំនួយនេះគឺសម្រាប់ផ្ដល់កម្ចីដល់ក្រុមសមាជិក ដែលពុំមានលទ្ធភាពទទួលបានឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងពីស្ថាប័នធនាគារផ្លូវការផ្សេងទៀតសម្រាប់គម្រោងវិនិយោគរបស់ខ្លួន។ គម្រោងនេះក៏នឹងភ្ជាប់ទំនាក់ទំនងសហព័ន្ធទាំងនេះជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ ដើម្បីឲ្យសហព័ន្ធទាំងនេះអាចទទួលបានឥណទានបន្ថែម/កាន់តែច្រើនក៏ដូចជាសេវាហិរញ្ញវត្ថុផ្សេងទៀត។

## *ការបង្កើនលទ្ធភាពចូលក្នុងទីផ្សារ*

17. គ្រួសារក្រីក្រក្នុងខេត្តសៀមរាបពឹងផ្អែកលើប្រព័ន្ធផលិតកម្មដែលរាំងស្ទះដោយកង្វះហិរញ្ញវត្ថុ និងកង្វះព័ត៌មាន ធនធាន ហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារ។ ក្នុងន័យនេះ គម្រោងនឹងជួយផ្ដល់ការបណ្ដុះបណ្ដាល និងសេវាទំនាក់ទំនងទីផ្សារ ដល់ក្រុមអ្នកទទួលផល។ សេវាទាំងនេះនឹងផ្ដោតលើការបង្កើនប្រសិទ្ធភាពផលិតកម្ម ការលើកកម្ពស់ផលិតភាព ការទទួលបានការផ្សព្វផ្សាយពីបច្ចេកវិទ្យា ហេដ្ឋា-រចនាសម្ព័ន្ធបម្រើដល់ការងារភ័ស្តុភារ និងសេវាព័ត៌មាន ក៏ដូចជាកសាងនូវប្រព័ន្ធទីផ្សារគាំទ្រជនក្រីក្រសម្រាប់អ្នកផលិតខ្នាតតូច និងអ្នកផលិតតូចតាច។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈបុគ្គលិកថ្នាក់ខេត្ត និងថ្នាក់ស្រុក នឹងចូលរួម និងទទួលជំនួយពី SMT ក្នុងការផ្ដល់សេវាគាំទ្រតាមតម្រូវការដើម្បីឆ្លើយតបនឹងតម្រូវការរបស់ក្រុមអ្នកទទួលផល និងភាពចាំបាច់ក្នុងសំណើ MIPs និង CLIF របស់ពួកគេ។ កម្មវិធីការងារប្រចាំឆ្នាំសម្រាប់ក្រសួងនឹងត្រូវបានព្រមព្រៀងជាមួយ SMT ជារៀងរាល់ឆ្នាំទៅតាមតម្រូវការ និងព័ត៌មានបច្ចុប្បន្នភាព។ នៅតាមមូលដ្ឋាន គម្រោងនឹងជួយដល់ការចូលរួម

របស់ CEWs និងពេទ្យសត្វឃុំ (CAHWs)។ ប្រសិនបើ និងក្នុងករណីចាំបាច់ អ្នកជំនាញផ្សេងទៀតមកពី និងក្រៅក្រសួង នឹងជួយផ្តល់ជំនួយបច្ចេកទេស និងការគ្រប់គ្រង។

18. *អនុសមាសភាគ១.២ ៖ លើកកម្ពស់ជំនាញនិងឪកាសការងារសម្រាប់ប្រជាពលរដ្ឋក្រីក្រតាមជនបទ (១,៩៦ លានដុល្លា)*-ការងារទទួលបានប្រាក់ឈ្នួលតែងពាក់ព័ន្ធនឹងគំរូប្រើប្រាស់ និងប្រាក់ចំណូលសមស្របសម្រាប់គ្រួសារដោយសារកម្រិតប៉ាន់ស្មានខ្ពស់នៃប្រាក់ចំណូល។ ប៉ុន្តែដើម្បីបង្កើនអត្ថប្រយោជន៍របស់ការងារទទួលប្រាក់ឈ្នួលក្នុងមូលដ្ឋាន កម្មករត្រូវការព័ត៌មានស្តីពីទីផ្សារការងារ និងឱកាសការងារ និងជំនាញ និងចំណេះដឹងសម្រាប់ធ្វើការល្អប្រសើរដែលបំពេញតម្រូវការទីផ្សារការងារ។ នៅខេត្តសៀមរាប ចំងាយទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាល ថ្លៃសិក្សា កង្វះព័ត៌មានស្តីពីឱកាសការងារ និងលក្ខខណ្ឌជំនាញ និងចំងាយទៅមជ្ឈមណ្ឌលការងារ ជាឧបសគ្គចម្បងក្នុងការរកបានការងារល្អ។ គម្រោងនឹងដោះស្រាយបញ្ហាប្រឈមទាំងនេះដើម្បីទាញយកឱកាសការងារក្នុងវិស័យឧស្សាហកម្មទេសចរណ៍ដែលកំពុងលូតលាស់ និងការអភិវឌ្ឍពាក់ព័ន្ធក្នុងខេត្ត។

19. អនុសមាសភាគនេះនឹងផ្តល់នូវច្រកបំពេញបន្ថែមសម្រាប់ការប្រកបមុខរបរចិញ្ចឹមជីវិតដល់ក្រុមជួយខ្លួនឯង ក៏ដូចជាផ្តល់នូវលទ្ធភាពចូលរួមក្នុងសង្វាក់ផ្គត់ផ្គង់និងទីផ្សារក្រោមអនុសមាសភាគ ១.១ ដោយវិនិយោគលើការអភិវឌ្ឍជំនាញរបស់អ្នកទទួលផល (ជាពិសេសយុវជនដែលគ្មានការងារធ្វើនិងស្ត្រីមកពីគ្រួសារក្រីក្រ) ក៏ដូចជាលើការបង្កើនសមត្ថភាពរបស់ពួកគេដើម្បីទទួលបានការងារថ្មីធ្វើ ឬការងារដែលមានប្រាក់ឈ្នួលខ្ពស់ជាងមុន។ សកម្មភាពរួមមាន (ក) ការអង្កេតទីផ្សារការងារក្នុងមូលដ្ឋាន និងការវាយតម្លៃអ្នកផ្តល់សេវាបណ្តុះបណ្តាល (ខ) ការជ្រើសរើសអ្នកទទួលផលគោលដៅ (គ) ការបណ្តុះបណ្តាលជំនាញដែលអាចរកការងារធ្វើបាន និងការផ្តល់ប្រឹក្សាអាជីព (ឃ) ការបណ្តុះបណ្តាលជំនាញដោយប្រើប្រាស់ប្រព័ន្ធប័ណ្ណ (voucher) (ង) ការស្វែងរកការងារឲ្យធ្វើនិងការគាំទ្រសម្រាប់ការបំពេញការងារ។

### *ការអង្កេតទីផ្សារការងារក្នុងមូលដ្ឋាន និងការវាយតម្លៃអ្នកផ្តល់សេវាបណ្តុះបណ្តាល*

20. ការវាយតម្លៃតម្រូវការនឹងធ្វើឡើងក្នុងរយៈពេល ៦ ខែ ដំបូងនៃការអនុវត្តសកម្មភាពទីមួយដែលធ្វើឡើងដោយអ្នកផ្តល់សេវាអភិវឌ្ឍន៍ធនធានមនុស្ស (HRDSP) ចុះកិច្ចសន្យាដោយក្រសួងមហាផ្ទៃដើម្បីជួយកំណត់និន្នាការទីផ្សារការងារក្នុងមូលដ្ឋាន និងតម្រូវការការងារជាក់លាក់ និង/ឬជំនាញបច្ចេកទេសដោយនិយោជកក្នុងតំបន់នៅជិតឃុំគោលដៅ។ HRDSP នឹងវាយតម្លៃគុណភាពរបស់អ្នកផ្តល់សេវាបណ្តុះបណ្តាលក្នុងមូលដ្ឋានដើម្បីកំណត់ជម្រើសក្នុងការបណ្តុះបណ្តាល។ គម្រោងនឹងកំណត់ និងចរចាកិច្ចព្រមព្រៀងជាមួយអ្នកផ្តល់ការបណ្តុះបណ្តាលដើម្បីផ្តល់កញ្ចប់សកម្មភាពបំពេញបន្ថែម ដូចជា ការបង្ហាញពីឱកាសទទួលបានការងារដែលមានប្រាក់ឈ្នួល ការផ្តល់ជំនាញទន់ ការពិគ្រោះយោបល់ ការបណ្តុះបណ្តាលពីការស្វែងរកការងារ និងសេវាផ្គូរផ្គងការងារ។ គម្រោងផ្តោតសំខាន់លើអ្នកផ្តល់ការបណ្តុះបណ្តាលដែលទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) ឬទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ដោយមានកំណត់ត្រាទទួលស្គាល់ និងការអនុវត្តល្អក្នុងកំណត់ការជួលរបស់និយោជក និងដែលអាចផ្តល់សិក្ខាកាមនូវសញ្ញាបត្របញ្ជាក់ក្រោយ

បញ្ចប់កម្មវិធី។ ក្នុងផ្នែកសាធារណៈ គម្រោងអាចផ្តល់លទ្ធភាពជម្រើសបណ្តុះបណ្តាលដើម្បីបំពេញបន្ថែមគម្រោង TVETSDP ដែលទទួលមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី និងដឹកនាំដោយ MoLVT ជាពិសេសជម្រើសការបណ្តុះបណ្តាលតាមមជ្ឈមណ្ឌល និងសហគ្រាសរបស់ពួកគេ។

21. គម្រោងនឹងជំរុញការចូលរួមជាប្រព័ន្ធជាមួយនិយោជកនានា ទីភ្នាក់ងារផ្គូរផ្គងការងារ/អង្គការមិនមែនរដ្ឋាភិបាល និងវេទិកាសេវាការងារសាធារណៈរបស់ក្រសួងការងារ ដើម្បីកែសម្រួលការផ្តល់វគ្គបណ្តុះបណ្តាល។ ក្នុងកម្រិតសមស្រប គម្រោងនឹងកំណត់ទាំងការបណ្តុះបណ្តាល និងឱកាសការងារដែលនៅជិតផ្ទះរបស់សិក្ខាកាម។

### *ការជ្រើសរើសអ្នកទទួលផល*

22. ការផ្តល់ជំនួយអភិវឌ្ឍន៍ជំនាញសំដៅគ្របដណ្តប់លើប្រជាជន ១.៣៥០ នាក់ក្នុងខេត្តសៀមរាប។ សកម្មភាពនឹងផ្តោតលើប្រជាជនមកពីគ្រួសារ IDPoor កម្រិត ១ និង ២ និងគ្រួសារដែលមិនបានចុះឈ្មោះក្នុងការអប់រំក្នុង និងក្រៅប្រព័ន្ធ ឬវគ្គបណ្តុះបណ្តាលនានា។ ក្រៅពីនេះ ប្រជាជនមិនក្រីក្រអាចទទួលបានប្រយោជន៍ពីកម្មវិធី ប្រសិនបើពួកគេបំពេញលក្ខខណ្ឌកំណត់ដែលសំដៅឆ្លុះបញ្ចាំងពីវិធីសាស្ត្រ IDPoor។ ស្វ័យជ្រើសរើសគឺជាវិធីបឋមសម្រាប់ការកំណត់បេក្ខជន ប៉ុន្តែក្រុមប្រឹក្សាឃុំ ក្រុមជួយខ្លួនឯង និង SLFs នឹងត្រូវបានស្នើឲ្យកំណត់ និងជំរុញអ្នកចូលរួមនានា ជាពិសេសស្ត្រី និងយុវជនគ្មានការងារធ្វើក្នុងសហគមន៍របស់ខ្លួន។ ដោយសារតែបញ្ហាចំងាយ កម្មវិធីនឹងផ្តោតលើសហគមន៍ដែលនៅជិតកន្លែងបណ្តុះបណ្តាល និងឱកាសការងារ។

23. គណៈកម្មាធិការពិនិត្យ/ជ្រើសរើសក្នុងឃុំនីមួយៗនឹងបង្កើតឡើងសម្រាប់ដំណើរការជ្រើសរើស។ គណៈកម្មាធិការនេះរួមមាន DFs សមាជិកក្រុមប្រឹក្សាឃុំ ក្រុមជួយខ្លួនឯង និង CLFs។ ពួកគេត្រូវកំណត់ និងផ្ទៀងផ្ទាត់ IDPoor ពិនិត្យអ្នកចូលរួមដែលមិនមែនជា IDPoor វាយតម្លៃលក្ខណសម្បត្តិរបស់អ្នកដាក់ពាក្យសុំ និងកម្រិតជំនាញ កម្រិតអប់រំ និងការបណ្តុះបណ្តាលរបស់អ្នកចូលរួម។ ប្រសិនបើចំនួនប្រជាជនមានគុណវុឌ្ឍិលើសពីចំនួនអតិបរមាកំណត់ដោយគម្រោងក្នុងមួយឃុំ/ឆ្នាំ ត្រូវមានចំនួនអ្នកចូលរួមជាស្ត្រី និងបុរសស្មើគ្នា ហើយដំណើរការជ្រើសរើសនឹងធ្វើដោយការចាប់ឆ្នោតចៃដន្យដើម្បីធានាភាពយុត្តិធម៌។ អាទិភាពគឺ IDPoor កម្រិតទី ១, IDPoor កម្រិតទី ២ រួចទើបបុគ្គលដែលមិនមែនជា IDPoor ប៉ុន្តែបំពេញលក្ខខណ្ឌគុណវុឌ្ឍិ IDPoor។

24. អ្នកផ្តល់សេវាអភិវឌ្ឍន៍ធនធានមនុស្ស (HRDSP) នឹងជួយដល់គណៈកម្មាធិការនេះក្នុងការបំពេញដំណើរការជ្រើសរើស និងអនុវត្តសកម្មភាពភាគច្រើនក្នុងអនុសមាសភាគនេះ។

### *ការបណ្តុះបណ្តាលជំនាញដែលអាចរកការងារធ្វើបាន និងការផ្តល់ប្រឹក្សាអាជីព*

25. ក្រោយទទួលឲ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ជំនាញរបស់គម្រោង បេក្ខជននឹងចូលរួមក្នុងសិក្ខាសាលាណែនាំ និងផែនការអភិវឌ្ឍន៍ជំនាញដែលរៀបចំដោយ HRDSP។ សិក្ខាសាលានឹងរួមបញ្ចូលធាតុផ្សំដូចជា ៖ (ក) ការបង្ហាញពីគោលបំណង និងជំនួយដែលផ្តល់ក្រោមអនុសមាសធាតុ

"ការបង្កើនជំនាញ និងឱកាសការងារ" (ខ) ព័ត៌មានស្តីពីទីផ្សារការងារក្នុងមូលដ្ឋាន ការបណ្តុះបណ្តាលអភិវឌ្ឍន៍អាជីព និងការរៀបចំផែនការអភិវឌ្ឍន៍ជំនាញ (គ) ការផ្តល់ការបណ្តុះបណ្តាលជំនាញការងារ "ទន់" ដូចជា របៀបរកការងារ ក្តីរំពឹងរបស់និយោជក។ល។ ក្រោយបញ្ចប់ផែនការអភិវឌ្ឍន៍ជំនាញ អ្នកចូលរួមនឹងកំណត់កម្មវិធីបណ្តុះបណ្តាលគួរឲ្យចាប់អារម្មណ៍ចេញពីតារាងស្ថាប័នបណ្តុះបណ្តាលដែលផ្តល់ដោយគម្រោង។ អ្នកចូលរួមនឹងត្រូវបានស្នើឲ្យជ្រើសរើសស្ថាប័នបណ្តុះបណ្តាលបន្ថែម ប្រសិនបើមិនទាន់មានក្នុងតារាង ហើយស្ថាប័នទាំងនេះនឹងត្រូវពិនិត្យដោយ HRDSP ដើម្បីឲ្យដឹងថាតើបំពេញលក្ខខណ្ឌគុណវុឌ្ឍិ ឬទេ។ ប្រសិនបើបំពេញលក្ខខណ្ឌ និងយល់ព្រមផ្តល់ជំនួយចាំបាច់ក្នុងគម្រោង ស្ថាប័នទាំងនេះនឹងត្រូវបញ្ចូលក្នុងតារាង។

26. ឱកាសសម្រាប់ការពិគ្រោះយោបល់អាជីពមួយទល់មួយ ក៏នឹងបញ្ចូលទៅក្នុងទម្រង់សិក្ខាសាលាផងដែរ និងបន្តធ្វើឡើងក្រោយបញ្ចប់សិក្ខាសាលាទៅតាមតម្រូវការ។ អ្នកដែលបញ្ចប់សកម្មភាព និងរៀបចំផែនការអភិវឌ្ឍន៍ជំនាញពេញលេញនឹងបន្តទៅជំហានបន្ទាប់ក្នុងដំណើរការនេះ។

### *ការបណ្តុះបណ្តាលជំនាញដោយប្រើប្រាស់ប្រព័ន្ធប័ណ្ណ (voucher)*

27. HRDSP នឹងពិនិត្យឡើងវិញលើផែនការអភិវឌ្ឍន៍ជំនាញទាំងអស់ និងអ្នកផ្តល់ការបណ្តុះបណ្តាលដែលផ្តល់ដោយអ្នកចូលរួមដើម្បីផ្តល់យោបល់ពីកញ្ចប់បណ្តុះបណ្តាលសម្រាប់អ្នកចូលរួមម្នាក់ៗ។ វគ្គបណ្តុះបណ្តាលដែលត្រូវផ្តល់នឹងត្រូវបែងចែកជាកម្រិត ១ (CQF 1) ក្រោមក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា (CQF) វគ្គខ្លី ការអប់រំបណ្តុះណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) រយៈពេល ២-៤ សប្តាហ៍ និងជំនួយមានកំណត់ជាច្រើនសម្រាប់វគ្គរយៈពេលវែង (រហូតដល់ ១២ ខែ) នៅកម្រិត CQF 2។ ការពិគ្រោះយោបល់ក្នុងពេលរៀបចំគម្រោងកំណត់ចំណាប់អារម្មណ៍លើជំនាញ និងការងារជាច្រើនដូចជា ជួសជុលម៉ូតូ កាត់ដេរ និងសេវាបដិសណ្ឋាកិច្ច។ ប្រភេទវគ្គបណ្តុះបណ្តាលដែលត្រូវទទួលជំនួយក្រោមគម្រោងនឹងមានភាពបត់បែន ដើម្បីឲ្យអ្នកចូលរួមអាចស្នើប្រធានបទដែលអាចមិនមែនជាប្រធានបទក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារការងារ និងមានអ្នកផ្តល់ការបណ្តុះបណ្តាលសមស្រប។ ថ្លៃបណ្តុះបណ្តាលគឺរហូតដល់ ៣០០ ដុល្លាសម្រាប់វគ្គខ្លី និង ៦០០ ដុល្លាសម្រាប់វគ្គរយៈពេលវែង។ គម្រោងនឹងផ្តល់សាហ៊ុយធ្វើដំណើរ អាហារ និងការស្នាក់នៅ ប្រសិនបើចាំបាច់ដើម្បីសម្របសម្រួលការចូលរួមរបស់អ្នកទទួលផល។

28. បន្ទាប់ពីការបញ្ជាក់របស់អ្នកចូលរួមពីកញ្ចប់វគ្គបណ្តុះបណ្តាលដែលគាំទ្រដោយគម្រោង កិច្ចព្រមព្រៀងមួយនឹងត្រូវចុះហត្ថលេខារវាងគម្រោង និងអ្នកចូលរួម និងរវាងគម្រោង និងអ្នកផ្តល់ការបណ្តុះបណ្តាល។ ភាគីនីមួយៗនឹងយល់ព្រមទទួលយកការទទួលខុសត្រូវនានាក្រោមកិច្ចព្រមព្រៀង។ អ្នកចូលរួមនឹងទទួលបានប័ណ្ណ (voucher) ដែលពួកគេអាចដាក់ជូនអ្នកផ្តល់ការបណ្តុះបណ្តាលដែលអាចត្រូវបានទូទាត់ជាមួយគម្រោង។

*ការស្វែងរកការងារធ្វើ និងការគាំទ្រសម្រាប់ការបំពេញការងារ*

29. ការទទួលខុសត្រូវចម្បងមួយរបស់អ្នកផ្តល់ការបណ្តុះបណ្តាលគឺពួកគេត្រូវជួយអ្នកចូលរួមក្នុងការកំណត់ និងទទួលបានការងារក្រោយបញ្ចប់ការបណ្តុះបណ្តាល។ HRDSP នឹងពិនិត្យជំនួយរបស់អ្នកផ្តល់ការបណ្តុះបណ្តាលក្នុងន័យនេះ និងជំរុញឲ្យមានជំនួយបន្ថែមប្រសិនបើចាំបាច់។ HRDSP នឹងតាមដានការទទួលបានការងាររបស់អ្នកចូលរួម និងធ្វើការសិក្សាតាមដានដើម្បីកំណត់ថាតើអ្នកចូលរួមនៅបន្តធ្វើការក្នុងមុខតំណែងថ្មី និងផលប៉ះពាល់របស់ការងារលើជីវភាពរបស់ពួកគេ។ ក្រុមប្រឹក្សាឃុំ ក្រុមជួយខ្លួនឯង និង CLFs នឹងតាមដានជាមួយសិក្ខាកាមដើម្បីជំរុញវត្តមានរបស់ពួកគេ ផ្តល់ជំនួយផ្នែកភស្តុភារ/ការធ្វើដំណើរ និងតាមដានវឌ្ឍនភាពរបស់ពួកគេក្នុងការបញ្ចប់វគ្គ និងស្ថានភាពក្រោយការបណ្តុះបណ្តាល/ការងារ។

30. ***អនុសមាសភាគ១.៣ ៖ ការលើកកម្ពស់សេវាជាមូលដ្ឋាន និងកែលំអហេដ្ឋារចនាសម្ព័ន្ធសហគមន៍សម្រាប់ប្រជាជនក្រីក្រ (៤,២៥ លានដុល្លា)***-សមាសភាគនេះនឹងសម្របសម្រួលការផ្តល់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចខ្នាតតូច ដែលឆ្លើយតបនឹងតម្រូវការអាទិភាពរបស់គ្រួសារក្រីក្រក្នុងឃុំគោលដៅ និងជួយដល់សក្តានុពលរកប្រាក់ចំណូលរបស់ពួកគេ។ ការឆ្លើយតបនឹងតម្រូវការបង្កើនផលិតភាព ភាពធន់ និងភាពស៊ាំទៅនឹងវិបត្តិធម្មជាតិ និងសេដ្ឋកិច្ច រួមមានលទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹក និងសេវាអនាម័យដែលអាចទុកចិត្ត និងតម្លៃសមរម្យ ការស្តុកទុក ឬឃ្លាំងតូច គម្រោងធារាសាស្រ្តខ្នាតតូច ផ្លូវចូលទៅកាន់សហគមន៍ និងការគ្រប់គ្រងទឹកក្នុងកសិដ្ឋានល្អប្រសើរ។

31. ការកំណត់តម្រូវការអាទិភាពក្នុងសហគមន៍ក្រីក្រនឹងអនុវត្តតាមដំណើរការរៀបចំផែនការ និងកំណត់អត្តសញ្ញាណដែលមានការចូលរួមប្រចាំឆ្នាំ និងមានស្រាប់ ដែលបង្កើតជាផែនការវិនិយោគឃុំ (CIP) និងបង្កើនសិទ្ធិអំណាចរបស់អ្នកទទួលផលគោលដៅសំខាន់ៗដើម្បីគាំទ្រអាទិភាពវិនិយោគរបស់ពួកគេ។ គម្រោងនឹងជួយដល់ការចូលរួមយ៉ាងសកម្មរបស់គ្រួសារ IDPoor ក្នុងការដំណើរការកំណត់ និងរៀបចំផែនការសម្រាប់សំណើ CIP ដែលលើកឡើងពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច។ ការបែងចែកមូលនិធិសម្រាប់ជួយដល់សំណើវិនិយោគអាទិភាពនឹងគណនាទៅតាមចំនួនគ្រួសារ IDPoor ក្នុងមួយឃុំ។ ការបែងចែកមធ្យម/ឃុំគឺប្រមាណ ៨៥.០០០ ដុល្លា សម្រាប់អំឡុងពេលគម្រោង។ ក្រោយការរៀបចំផែនការឆ្នាំដំបូង ទឹកប្រាក់នៃផ្តល់ជូនសម្រាប់ការចំណាយរយៈពេលជាង ៣ ឆ្នាំ ឬ ៤ ឆ្នាំ ទៅតាមចំណាយរបស់អនុគម្រោងដែលជ្រើសរើសសម្រាប់ហិរញ្ញប្បទានដោយឃុំ។ ឃុំមួយអាចរួមបញ្ចូលមូលនិធិគម្រោងជាមួយមូលនិធិមកពីប្រភពផ្សេង នៅពេលធ្វើការវិនិយោគ។ អនុគម្រោងរហូតដល់ ១៨៨ នឹងត្រូវបានអនុវត្តក្នុងអំឡុងពេលគម្រោង ប្រសិនបើឃុំទាំង ៤៧ ត្រូវអនុវត្តអនុគម្រោង ៤ ក្នុងមួយឃុំ។

32. ការអនុវត្តការវិនិយោគហេដ្ឋារចនាសម្ព័ន្ធនឹងអនុវត្តតាមនីតិវិធីដែលគ្រោងក្នុងសៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (CSF PIM)។ នៅពេលអនុគម្រោងត្រូវបានជ្រើសរើសសម្រាប់ផ្តល់ហិរញ្ញវត្ថុ នីតិវិធី CSF PIM លើកលែងតែយន្តការទូទាត់ ត្រូវបានចាប់ផ្តើមពីការពិនិត្យការពារ និងការបង្កើតគណៈកម្មាធិការគ្រប់គ្រងគម្រោង។ ក្រុមប្រឹក្សាឃុំដឹកនាំដំណើរការនេះ ដូចជា លទ្ធកម្ម និងការ

គ្រប់គ្រងអ្នកម៉ៅការ និងដោយមានជំនួយពីអង្គភាពគាំទ្របច្ចេកទេសរបស់រដ្ឋបាលខេត្ត និងស្រុក។ ដើម្បីបំពេញបន្ថែមលើសមត្ថភាពរបស់ក្រុមបច្ចេកទេសខេត្ត និងស្រុក នឹងមានអ្នកជំនាញហេដ្ឋារចនា-សម្ព័ន្ធម្នាក់សម្រាប់ជាផ្នែកមួយនៃ SMT ដើម្បីត្រួតពិនិត្យដំណើរការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ផ្តល់ជំនួយបច្ចេកទេស និងការពិនិត្យតាមដាន និងជួយដល់ក្រុមប្រឹក្សាឃុំក្នុងការពិនិត្យ និងគ្រប់គ្រងកិច្ចសន្យា។

**សមាសភាគ ២ ៖ ការលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងទីក្រុង (៣,៧២លានដុល្លារ)**

33. សមាសភាគនេះមានគោលបំណងឆ្លើយតបចំពោះតម្រូវការរបស់គ្រួសារ IDPoor និងគ្រួសារងាយរងគ្រោះក្នុងសង្កាត់ចំនួន ១៣ ក្នុងរាជធានីភ្នំពេញដោយប្រើប្រាស់វិធីសាស្ត្រផ្អែកតាមតម្រូវការ។ សកម្មភាពនានារួមមាន៖ (ក) ការបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញ (ខ) ការអភិវឌ្ឍជំនាញសេវាគាំទ្រការងារ/មុខរបរនិងការបណ្តុះបណ្តាលការងារ និង (គ) ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ផលិតកម្មដើម្បីលើកកម្ពស់ជីវភាពរស់នៅនិងបង្កើនផលិតភាព។ សមាសភាគនេះនឹងអនុវត្តដោយសាលារាជធានីភ្នំពេញតាមរយៈអនុសមាសភាគខាងក្រោម ៖

34. **សមាសភាគ ២.១ ៖ លើកកម្ពស់ជំនាញនិងឪកាសការងារ/មុខរបរសម្រាប់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុង** (**១**,**៦៩ លានដុល្លា)**-ឱកាសធ្វើការងារមានប្រាក់ឈ្នួលក្នុងតំបន់ប្រជុំជននៅភ្នំពេញបង្កើតជាផ្នែកកាន់តែសំខាន់នៃរបរចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រក្នុងទីក្រុងជាងក្នុងតំបន់ជនបទ។ ហើយខណៈដែលមានកំណើនការងារថ្មីៗក្នុងក្រុងភ្នំពេញ ដូចជា សំណង់ និងរោងចក្រកាត់ដេរ មុខតំណែងក្នុងវិស័យទាំងនេះតែងតែជាការងារមិនអាចទុកចិត្តបាន និងធម្មតាដែលផ្តល់ប្រាក់ឈ្នួលទាប និងមិនសូវមានឱកាសឡើងតំណែង។ ដើម្បីទទួលបានសក្តានុពលការងារដែលផ្តល់ប្រាក់ឈ្នួលខ្ពស់ និងឋិតថេរដូចក្នុងតំបន់ជនបទដែរ កម្មករត្រូវការព័ត៌មានដែលអាចទុកចិត្តបានស្តីពីទីផ្សារការងារ និងឱកាសការងារ និងជំនាញការងារ និងចំណេះដឹងល្អប្រសើរដែលបំពេញតម្រូវការទីផ្សារការងារ។

35. អនុសមាសភាគនេះនឹងផ្តល់ការវិនិយោគលើការអភិវឌ្ឍជំនាញរបស់អ្នកទទួលផល (ជាពិសេសយុវជន និងស្ត្រីគ្មានការងារមកពីគ្រួសារក្រីក្រ) និងសមត្ថភាពក្នុងការទទួលបានការងារថ្មី ឬការងារដែលផ្តល់ប្រាក់ឈ្នួលខ្ពស់ ដូចជា ការទាញប្រយោជន៍ពីឱកាសដែលផ្តល់ដោយសហគ្រាសខ្នាតតូចមធ្យម និងធំក្នុងទីក្រុងភ្នំពេញ។ ក្នុងអនុសមាសភាគជនបទ ១.២ សកម្មភាពរួមមាន (ក) ការអង្កេតទីផ្សារការងារក្នុងមូលដ្ឋាន និងការវាយតម្លៃអ្នកផ្តល់សេវាបណ្តុះបណ្តាល (ខ) ការជ្រើសរើសអ្នកទទួលផលគោលដៅ(គ) ការបណ្តុះបណ្តាលជំនាញដែលអាចរកការងារធ្វើបាននិងការផ្តលប្រឹក្សាអាជីព (ឃ) ការបណ្តុះបណ្តាលជំនាញដោយប្រើប្រាស់ប្រព័ន្ធប័ណ្ណ (voucher) (ង) ការស្វែងរកការងារឲ្យធ្វើ និងការគាំទ្រសម្រាប់ការបំពេញការងារ។

36. គម្រោងនឹងដោះស្រាយបញ្ហាប្រឈមទាំងនេះក្នុងតំបន់ប្រជុំជនក្នុងលក្ខណៈស្រដៀងគ្នាបំផុតនឹងតំបន់ជនបទដែលមានរៀបចំក្នុងអនុសមាសភាគ ១.២។ គេរំពឹងថា គម្រោងនឹងប្រើប្រាស់តែអ្នកផ្តល់

សេវាអភិវឌ្ឍន៍ធនធានមនុស្ស (HRDSP) តែមួយប៉ុណ្ណោះសម្រាប់ទីក្រុងភ្នំពេញ និងខេត្តសៀមរាប។ អ្នកជំនាញអភិវឌ្ឍន៍ធនធានមនុស្សនឹងត្រូវបានជួលឲ្យធ្វើការក្នុង SMT នីមួយៗដើម្បីសម្របសម្រួលការងាររបស់ HRDSP ក្នុងទីតាំងនីមួយៗ និងសម្របសម្រួលតួនាទីរបស់ស្រុក និងឃុំ។

37. ***អនុសមាសភាគ ២.២ ៖ ការលើកកម្ពស់សេវាមូលដ្ឋាននិងហេដ្ឋារចនាសម្ព័ន្ធសហគមន៍សម្រាប់ប្រជាជនក្រីក្រក្នុងទីប្រជុំជន (២,០៣ លានដុល្លា)-***សមាសភាគនេះនឹងអនុវត្តតាមដំណើរការដូចគ្នាក្នុងសមាសភាគ ១.៣ ដែរ និងប្រើប្រាស់ CSFPIM។ ដើម្បីធានាយ៉ាងណាឲ្យអនុគម្រោងអាចផ្តល់ប្រយោជន៍ច្រើនបំផុតដល់គ្រួសារក្រីក្រនិងងាយរងគ្រោះដូចជាសហគមន៍ក្រីក្រក្នុងទីក្រុងជាដើម កិច្ចប្រជុំរៀបចំផែនការសហគមន៍នឹងមានការចូលរួមពីគ្រួសារ IDPoor ផងនិងតំណាងសហគមន៍ក្រីក្រក្នុងទីក្រុងផង។ ប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលនឹងទទួលបានថវិកាគាំទ្ររួមមាន ប៉ុន្តែមិនកំណត់ត្រឹមប្រព័ន្ធលូផ្លូវ/ផ្លូវដើរក្នុងសហគមន៍ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអនាម័យ និងភ្លើងបំភ្លឺផ្លូវជាដើម។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ទាំងនេះ គឺត្រូវបានកំណត់ក្នុងការអង្កេតវាយតម្លៃលើតម្រូវការរបស់សហគមន៍ក្រីក្រក្នុងទីក្រុងហើយមានការរំពឹងថា ការវិនិយោគទាំងនេះនឹងបង្កើនផលិតភាព ភាពធន់ទ្រាំ និងលទ្ធភាពរបស់អ្នកទទួលផលក្នុងការសម្របខ្លួនទៅតាមវិបត្តិធម្មជាតិ និងសេដ្ឋកិច្ច។

38. ការកំណត់តម្រូវការអាទិភាពក្នុងសហគមន៍ក្រីក្រនឹងអនុវត្តតាមដំណើរការរៀបចំផែនការ និងកំណត់អត្តសញ្ញាណដែលមានការចូលរួមប្រចាំឆ្នាំ និងមានស្រាប់ ដែលបង្កើតជាផែនការវិនិយោគសង្កាត់ (SIP) និងបង្កើនសិទ្ធិអំណាចរបស់អ្នកទទួលផលគោលដៅសំខាន់ៗដើម្បីគាំទ្រអាទិភាពវិនិយោគរបស់ពួកគេ។ តាមរយៈអ្នកសម្របសម្រួលថ្នាក់ស្រុក គម្រោងនឹងជួយដល់ការចូលរួមយ៉ាងសកម្មរបស់គ្រួសារ IDPoor និងគ្រួសារសហគមន៍ក្រីក្រក្នុងទីក្រុងក្នុងដំណើរការកំណត់ និងរៀបចំផែនការសម្រាប់សំណើ SIP ដែលលើកឡើងពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច។ ការបែងចែកមូលនិធិសម្រាប់ជួយដល់សំណើវិនិយោគអាទិភាពនឹងគណនាទៅតាមចំនួនគ្រួសារ IDPoor ក្នុងមួយសង្កាត់។ ដោយសារតែចំណាយខ្ពស់លើការសាងសង់ និងហេដ្ឋារចនាសម្ព័ន្ធនៅភ្នំពេញ ការបែងចែកមធ្យម ក្នុងមួយសង្កាត់គឺប្រមាណ ១៣០.០០០ ដុល្លា សម្រាប់អំឡុងពេលគម្រោង។ ក្រោយការរៀបចំផែនការឆ្នាំដំបូង ទឹកប្រាក់នៃផ្តល់ជូនសម្រាប់ការចំណាយរយៈពេលជាង ៣ ឆ្នាំ ឬ ៤ ឆ្នាំ ទៅតាមចំណាយរបស់អនុគម្រោងដែលជ្រើសរើសសម្រាប់ហិរញ្ញប្បទានដោយសង្កាត់។ សង្កាត់មួយអាចរួមបញ្ចូលមូលនិធិគម្រោងជាមួយមូលនិធិមកពីប្រភពផ្សេង នៅពេលធ្វើការវិនិយោគ។ អនុគម្រោងរហូតដល់ ៥២ នឹងត្រូវបានអនុវត្តក្នុងអំឡុងពេលគម្រោង ប្រសិនបើសង្កាត់ទាំង ១៣ ត្រូវអនុវត្តអនុគម្រោង ៤ ក្នុងមួយសង្កាត់។

39. ការអនុវត្តការវិនិយោគហេដ្ឋារចនាសម្ព័ន្ធនឹងអនុវត្តតាមនីតិវិធីដែលគ្រោងក្នុងសៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (CSF PIM)។ នៅពេលអនុគម្រោងត្រូវបានជ្រើសរើសសម្រាប់ផ្តល់ហិរញ្ញវត្ថុ នីតិវិធី CSF PIM លើកលែងតែយន្តការទូទាត់ ត្រូវបានចាប់ផ្តើមពីការពិនិត្យការពារ និងការបង្កើតគណៈកម្មាធិការគ្រប់គ្រងគម្រោង។ ក្រុមប្រឹក្សាសង្កាត់ដឹកនាំដំណើរការនេះ ដូចជា លទ្ធកម្ម និងការគ្រប់គ្រងអ្នកម៉ៅការ និងដោយមានជំនួយពីអង្គភាពគាំទ្របច្ចេកទេសរបស់រដ្ឋបាលក្រុង និង

ខណ្ឌ។ ដើម្បីបំពេញបន្ថែមលើសមត្ថភាពរបស់ក្រុមបច្ចេកទេសក្រុង និងខណ្ឌ នឹងមានអ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធម្នាក់សម្រាប់ជាផ្នែកមួយនៃ SMT ដើម្បីត្រួតពិនិត្យដំណើរការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ផ្តល់ជំនួយបច្ចេកទេស និងការពិនិត្យតាមដាន និងជួយដល់ក្រុមប្រឹក្សាសង្កាត់ក្នុងការពិនិត្យ និងគ្រប់គ្រងកិច្ចសន្យា។

## សមាសភាគ ៣ ៖ ការគ្រប់គ្រងគម្រោង (៣,៩៧ លានដុល្លារ)

40. សមាសភាគនេះនឹងផ្តល់ការគាំទ្រដល់ការអនុវត្តការត្រួតពិនិត្យ និងការសម្របសម្រួលគម្រោងទាំងមូលនៅថ្នាក់ជាតិ ខេត្ត ស្រុក/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ/សហគមន៍ ដូចជា (ក) ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន (ខ) ការរៀបចំផែនការលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា (គ) ការគ្រប់គ្រងហិរញ្ញវត្ថុ ការទម្លាក់សាច់ប្រាក់ និងសវនកម្ម និង (ឃ) ការពិនិត្យតាមដាននិងវាយតម្លៃ និងការប្រាស្រ័យទាក់ទង។

41. សកម្មភាពនឹងរួមមាន ៖ (ក) ការបង្កើត និងប្រតិបត្តិការការិយាល័យសម្របសម្រួលគម្រោង (PCO) ក្រោមអគ្គលេខាធិការដ្ឋានរបស់ក្រសួងមហាផ្ទៃ (ខ) ការបង្កើត និងប្រតិបត្តិការក្រុមគ្រប់គ្រងរង (SMT) នៅសាលាខេត្តសៀមរាប និងសាលារាជធានីភ្នំពេញ (គ) ការចូលរួមរបស់ក្រុមអ្នកជំនាញបង្គោលនៅ PCO និង SMT ដើម្បីផ្តល់ជំនួយបច្ចេកទេស និងការណែនាំដល់សមាសធាតុនានា (ឃ) ការចូលរួមរបស់អ្នកសម្របសម្រួលថ្នាក់ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដើម្បីផ្តល់ជំនួយផ្ទាល់ដល់សកម្មភាពក្នុងសហគមន៍របស់ខ្លួន និង (ង) ការបង្កើត និងប្រតិបត្តិការលទ្ធកម្មគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។

42. ការអនុវត្តគម្រោងដោយប្រសិទ្ធភាពទាមទារការបង្កើតពីដំបូងនូវប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ ជាពិសេស ការអង្កេតទិន្នន័យគោល និងការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានមួយគឺជាសកម្មភាពអាទិភាពនៅពេលចាប់ផ្តើមគម្រោង។

## សមាសភាគទី ៤ ៖ ការបម្រុងឆ្លើយតបចំពោះស្ថានភាពអាសន្ន (0 លានដុល្លារ)

43. សមាសភាគនេះដែលមានការវិភាជន៍ថវិកាបឋមសូន្យដុល្លារគឺជាផ្នែកមួយនៃគាំទ្ររបស់ធនាគារពិភពលោក (IDA) លើយន្តការឆ្លើយតបបន្ទាន់ (IRM) ក្នុងប្រទេសកម្ពុជា។ IRM នឹងផ្តល់លទ្ធភាពឲ្យមានការវិភាជន៍ថវិកាដែលមិនបានទម្លាក់ដល់គម្រោង ដើម្បីគាំទ្រដល់ការស្តារ និងស្ថាបនាឡើងវិញក្រោយពីមានការស្នើសុំជាផ្លូវការពីរដ្ឋាភិបាលក្នុងករណីបន្ទាន់ណាមួយដែលគម្រោងអាចគាំទ្របាន។

44. ដោយមានជំនួយពី IDA រដ្ឋាភិបាលកម្ពុជាកំពុងតាក់តែងសៀវភៅណែនាំស្តីពីការឆ្លើយតបបន្ទាន់ (ERM) សម្រាប់គម្រោងទាំងអស់នៅកម្ពុជាដែលប្រើប្រាស់យន្តការនេះ។ សៀវភៅណែនាំនេះនឹងលម្អិតពីការប្រើប្រាស់សមស្រប ការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការធានាការពារ និងការរៀបចំការអនុវត្តផ្សេងទៀត។ ការរៀបចំ និងការទទួលយកសៀវភៅណែនាំនេះគឺជាលក្ខខណ្ឌមួយ មុនពេលទម្លាក់ថវិកាសម្រាប់សមាសភាគនេះ។ ក្នុងករណីដែលមានការប្រើប្រាស់ IRM ក្របខ័ណ្ឌលទ្ធផលនឹង

ត្រូវកែសម្រួលទៅតាមភាពចាំបាច់ តាមរយៈការរៀបចំរចនាសម្ព័ន្ធឡើងវិញផ្លូវការដើម្បីឆ្លុះបញ្ចាំងពីការផ្តល់ការឆ្លើយតបភ្លាមៗ និងមានប្រសិទ្ធភាពទៅនឹងវិបត្តិ ឬគ្រោះអាសន្ន។

## ការកំណត់ចំណុចដៅ និងការជ្រើសរើស

45. អ្នកទទួលផលសំខាន់ៗនៃគម្រោងគឺ IDPoor[4] និងគ្រួសារងាយរងគ្រោះក្នុងឃុំគោលដៅ ៤៧ ក្នុងខេត្តសៀមរាប និងសង្កាត់គោលដៅ ១៣ ក្នុងក្រុងភ្នំពេញ។ តារាងទី ១ និង ២ និងរូបលេខ ១ និង ២ ខាងក្រោមបង្ហាញផែនទី និងព័ត៌មានរបស់ស្រុក/ខណ្ឌ និងឃុំ និងសង្កាត់គោលដៅទាំងនោះ។

46. អ្នកទទួលផលក្នុងខេត្តសៀមរាបមកពីឃុំ ៤៧ ដែលមិនទទួលបានជំនួយពីគម្រោង TSSD។ មានឃុំ ៤២ ដែលមិនទទួលបានជំនួយពីគម្រោង TSSD ហើយឃុំទាំងនោះនឹងត្រូវគ្របដណ្តប់ទាំងស្រុងដោយគម្រោង LEAP។ ក្រៅពីនេះ មានឃុំ ៥ ដែលមិនទទួលបានជំនួយទាំងស្រុងពីគម្រោង TSSD ប៉ុន្តែមានកម្រិតភាពក្រីក្រខាងលើ ហើយភូមិក្នុងឃុំទាំងនេះនឹងត្រូវបញ្ចូលក្នុងគម្រោង LEAP។ តារាងទី១ ខាងក្រោមបង្ហាញពីស្រុក និងឃុំគោលដៅទាំងអស់នៅខេត្តសៀមរាប និងចំនួនអ្នកទទួលផលគោលដៅ។ រូបលេខ ១ ខាងក្រោម ជាផែនទីតំបន់គោលដៅ ដែលកំណត់ទីតាំងរបស់ឃុំគោលដៅ។

47. អ្នកទទួលផលក្នុងរាជធានីភ្នំពេញមកពីសង្កាត់ចំនួន ១៣ ក្នុងចំណោមសង្កាត់ចំនួន ១០៥ ដែលនឹងត្រូវជ្រើសរើស ដូចតទៅ ៖ (ក) សម្រាប់ខណ្ឌចំនួន៨ដែលមានទិន្នន័យ IDPoor សង្កាត់ដែលមានចំនួនគ្រួសារ IDPoor សរុបច្រើនជាងគេត្រូវបានជ្រើសរើស ពោលគឺសង្កាត់មួយត្រូវបានជ្រើសរើសចេញពីខណ្ឌនីមួយៗក្នុងចំណោមខណ្ឌទាំង ៦ ដើម្បីបានរហូតដល់ ១០ សង្កាត់ ឬតិចជាងនេះដោយក្នុងនោះមានសង្កាត់ចំនួនពីរត្រូវបានជ្រើសរើសចេញពីខណ្ឌនីមួយៗក្នុងចំណោមខណ្ឌចំនួនពីរ ដែលមានសង្កាត់ច្រើនជាង ១០ និង (ខ) សម្រាប់ខណ្ឌចំនួន ៤ ដែលពុំមានទិន្នន័យ IDPoor ដោយសារតែខណ្ឌទាំងនេះនៅចំកណ្តាលក្រុង មានការជ្រើសរើសសង្កាត់មួយក្នុងមួយខណ្ឌដែលមានចំនួនគ្រួសារសហគមន៍ក្រីក្រទីក្រុងសរុបខ្ពស់ជាងគេទៅតាមការកំណត់របស់សាលារាជធានីភ្នំពេញ។ ក្នុងករណីដែលពុំមានទិន្នន័យ IDPoor សម្រាប់ទីក្រុងទាំងមូល ការប្រើប្រាស់ IDPoor និងលក្ខណៈវិនិច្ឆ័យ UPC នឹងផ្តល់លទ្ធភាពឲ្យមានការដាក់បញ្ចូលខណ្ឌជាយក្រុង និងខណ្ឌកណ្តាលក្រុងបាន។ ចំណុចដៅសម្រាប់ការគ្របដណ្តប់ក្នុងរាជធានីភ្នំពេញនេះត្រូវបានកំណត់ឲ្យទាប ដើម្បីឲ្យមានការ

---

[4] ដោយសារតែការអង្កេត IDPoor ធ្វើឡើងរៀងរាល់បីឆ្នាំម្តង មេឃុំ និងចៅសង្កាត់ ត្រូវបានស្នើឲ្យកំណត់ពីគ្រួសារដែលអាចទទួលផលពីគម្រោងនេះ ពោលគឺជាគ្រួសារដែលអាចធ្លាក់ខ្លួនក្រ ចាប់គិតពីការអង្កេតចុងក្រោយមកដោយសារតែកត្តាសេដ្ឋកិច្ច (ការធ្លាក់ថ្លៃទំនិញ) គ្រោះមហន្តរាយធម្មជាតិ (គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ដំណាំទទួលរងការបំផ្លិចបំផ្លាញ) ឬវិបត្តិផ្សេងទៀត ផ្អែកទៅតាមកម្រងសំណួរ IDPoor។ គ្រួសារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាគ្រួសារ IDPoor ថ្មី នឹងត្រូវឆ្លងកាត់តេស្តកំណត់មធ្យមភាគតំណាង (proxy means test) ដោយប្រើប្រាស់វិធីសាស្ត្រ IDPoor ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាពួកគេពិតជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលផលពីគម្រោងនេះ។

អនុវត្តសាកល្បងសកម្មភាពគម្រោងក្នុងបរិបទទីក្រុងសិន ដោយមានសក្តានុពលពង្រីកបន្ថែមទៀតនៅពេលដែលគម្រោងវិវឌ្ឍទៅមុខទៀត។ តារាងទី ២ ខាងក្រោមបង្ហាញពីតារាងខណ្ឌ និងសង្កាត់គោលដៅទាំងអស់នៅភ្នំពេញ រួមទាំងចំនួនអ្នកទទួលផលគោលដៅ។ រូបលេខ ២ ខាងក្រោម គឺជាផែនទីតំបន់គោលដៅដែលកំណត់ទីតាំងរបស់សង្កាត់គោលដៅ។

# តារាងទី ១ ៖ ឃុំ និងអ្នកទទួលផលគោលដៅសម្រាប់សមាសភាគ ១ (ខេត្តសៀមរាប)

| ស្រុក (2015) | ឃុំដែលបានកំណត់និងស្នើឡើង (2015) | ភូមិដែលបានកំណត់និងស្នើឡើង (2015) | គ្រួសារសរុប (2015) | ក្រីក្រកម្រិត 1 (2015) | | | ក្រីក្រកម្រិត 2 (2015) | | | គ្រួសារក្រីក្រ 1&2 | ប្រជាជនក្រីក្រ 1&2 (%) | ចំណុចដៅសរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | គ្រួសារ | មនុស្ស | % | គ្រួសារ | មនុស្ស | % | | | ចំនួនឃុំ | ចំនួនភូមិ | គ្រួសារ IDPoor កម្រិត 1&2 (ចំនួន) |
| អង្គរធំ | ជប់តាត្រាវ | 5 | 828 | 79 | 343 | 9.5% | 111 | 477 | 13.4% | 190 | 22.9% | 1 | 5 | 190 |
| | លាងដៃ | 9 | 2256 | 264 | 1085 | 11.7% | 399 | 1664 | 17.7% | 663 | 29.4% | 1 | 9 | 663 |
| | ពាក់ស្នែង | 6 | 1203 | 182 | 719 | 15.1% | 192 | 812 | 16.0% | 374 | 31.1% | 1 | 6 | 374 |
| | ស្វាយចេក | 7 | 1417 | 76 | 289 | 5.4% | 259 | 1116 | 18.3% | 335 | 23.6% | 1 | 6 | 335 |
| | 4/4 | 27 | 5704 | 601 | 2436 | 10.5% | 961 | 4069 | 16.8% | 1562 | 27.4% | 4 | 26 | 1562 |
| ជីក្រែង | អន្លង់សំណ | 16 | 2753 | 75 | 252 | 2.7% | 347 | 1555 | 12.6% | 422 | 15.3% | 1 | 16 | 422 |
| | ជីក្រែង | 14 | 1976 | 152 | 665 | 7.7% | 369 | 1597 | 18.7% | 521 | 26.4% | 1 | 14 | 521 |
| | កំពង់ក្ដី | 16 | 2243 | 131 | 489 | 5.8% | 281 | 1239 | 12.5% | 412 | 18.4% | 1 | 16 | 412 |
| | គោកធ្លកក្រោម | 18 | 3187 | 426 | 1842 | 13.4% | 339 | 1630 | 10.6% | 765 | 24.0% | 1 | 18 | 765 |
| | ស្ពានត្នោត | 15 | 2205 | 257 | 1089 | 11.7% | 460 | 2037 | 20.9% | 717 | 32.5% | 1 | 15 | 717 |
| | 5/12 | 152 | 29440 | 2482 | 10302 | 8.4% | 3557 | 15618 | 12.1% | 6039 | 20.5% | 5 | 79 | 2837 |
| ក្រឡាញ់ | កំពង់ថ្កូវ | 8 | 1153 | 20 | 93 | 1.7% | 78 | 381 | 6.8% | 98 | 8.5% | 1 | 8 | 98 |
| | សំបួរ | 8 | 1529 | 63 | 243 | 4.1% | 140 | 558 | 9.2% | 203 | 13.3% | 1 | 8 | 203 |
| | 2/10 | 99 | 13901 | 376 | 1395 | 2.7% | 1064 | 4342 | 7.7% | 1440 | 10.4% | 2 | 16 | 301 |
| ពួក | សសរស្ដម្ភ | 14 | 2720 | 72 | 259 | 2.6% | 211 | 827 | 7.8% | 283 | 10.4% | 1 | 14 | 283 |
| | ដូនកែវ | 13 | 2807 | 210 | 780 | 7.5% | 332 | 1448 | 11.8% | 542 | 19.3% | 1 | 13 | 542 |
| | ក្ដីរុន | 7 | 1092 | 83 | 314 | 7.6% | 197 | 817 | 18.0% | 280 | 25.6% | 1 | 7 | 280 |
| | កែវពណ៌ | 8 | 1409 | 55 | 231 | 3.9% | 134 | 557 | 9.5% | 189 | 13.4% | 1 | 8 | 189 |
| | ខ្នាត | 12 | 2160 | 208 | 820 | 9.6% | 202 | 878 | 9.4% | 410 | 19.0% | 1 | 12 | 410 |
| | ល្វា | 12 | 2362 | 163 | 666 | 6.9% | 385 | 1712 | 16.3% | 548 | 23.2% | 1 | 12 | 548 |
| | មុខពាន | 6 | 1206 | 91 | 339 | 7.5% | 222 | 907 | 18.4% | 313 | 26.0% | 1 | 6 | 313 |
| | ពោធិ៍ទ្រាយ | 2 | 419 | 52 | 183 | 12.4% | 25 | 116 | 6.0% | 77 | 18.4% | 1 | 2 | 77 |
| | ព្រៃជ្រូក | 12 | 1883 | 62 | 240 | 3.3% | 131 | 598 | 7.0% | 193 | 10.2% | 1 | 12 | 193 |
| | រើល | 14 | 3017 | 416 | 1742 | 13.8% | 748 | 3286 | 24.8% | 1164 | 38.6% | 1 | 14 | 1164 |
| | សំរោងយា | 6 | 1278 | 42 | 176 | 3.3% | 109 | 451 | 8.5% | 151 | 11.8% | 1 | 6 | 151 |
| | ត្រើញ | 10 | 2005 | 247 | 1002 | 12.3% | 429 | 1832 | 21.4% | 676 | 33.7% | 1 | 10 | 676 |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | យៀង | 5 | 1002 | 98 | 346 | 9.8% | 175 | 728 | 17.5% | 273 | 27.2% | 1 | 5 | 273 |
| | 13/14 | 132 | 26140 | 1868 | 7343 | 7.1% | 3383 | 14518 | 12.9% | 5251 | 20.1% | 13 | 121 | 5099 |
| ប្រាសាទបាគង | បាគង | 6 | 1744 | 32 | 142 | 1.8% | 147 | 590 | 8.4% | 179 | 10.3% | 1 | 6 | 179 |
| | បាឡាំង | 8 | 1381 | 65 | 257 | 4.7% | 116 | 459 | 8.4% | 181 | 13.1% | 1 | 8 | 181 |
| | កំពង់ភ្លុក | 3 | 731 | 22 | 101 | 3.0% | 59 | 235 | 8.1% | 81 | 11.1% | 1 | 3 | 81 |
| | កន្ទ្រាញ | 8 | 2011 | 47 | 164 | 2.3% | 84 | 334 | 4.2% | 131 | 6.5% | 1 | 8 | 131 |
| | កន្ឡៀក | 10 | 2875 | 72 | 293 | 2.5% | 218 | 920 | 7.6% | 290 | 10.1% | 1 | 10 | 290 |
| | មានជ័យ | 6 | 1220 | 59 | 243 | 4.8% | 158 | 632 | 13.0% | 217 | 17.8% | 1 | 6 | 217 |
| | រលួស | 7 | 1630 | 152 | 670 | 9.3% | 141 | 643 | 8.7% | 293 | 18.0% | 1 | 7 | 293 |
| | ត្រពាំងធំ | 9 | 1883 | 145 | 586 | 7.7% | 130 | 575 | 6.9% | 275 | 14.6% | 1 | 9 | 275 |
| | 8/8 | 57 | 13475 | 594 | 2456 | 4.4% | 1053 | 4388 | 7.8% | 1647 | 12.2% | 8 | 57 | 1647 |
| សៀមរាប | ស្វាយដង្គុំ | 6 | 2566 | 107 | 510 | 4.2% | 242 | 1120 | 9.4% | 349 | 13.6% | 1 | 6 | 349 |
| | ចុងឃ្នៀស | 7 | 1320 | 141 | 709 | 10.7% | 121 | 621 | 9.2% | 262 | 19.8% | 1 | 7 | 262 |
| | សង្កាត់អំពិល | 10 | 1612 | 37 | 110 | 2.3% | 194 | 796 | 12.0% | 231 | 14.3% | 1 | 10 | 231 |
| | សង្កាត់ក្របីរាល | 12 | 1734 | 109 | 438 | 6.3% | 211 | 824 | 12.2% | 320 | 18.5% | 1 | 12 | 320 |
| | សង្កាត់ទឹកវិល | 10 | 2452 | 185 | 836 | 7.5% | 143 | 638 | 5.8% | 328 | 13.4% | 1 | 10 | 328 |
| | 5/13 | 94 | 32937 | 1570 | 7146 | 4.8% | 2898 | 13771 | 8.8% | 4468 | 13.6% | 5 | 45 | 1490 |
| | ដានរុន | 13 | 2640 | 180 | 723 | 6.8% | 312 | 1347 | 11.8% | 492 | 18.6% | 1 | 13 | 492 |
| សូត្រនិគម 49232cr)Srvr4mR(SD | កំពង់ប្លាំង rAD6&2C" | 10 | 2122 | 515 | 2287 | 24.3% | 340 | 1585 | | | | | | |